ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

## ផែនការយុទ្ធសាស្ត្រ

## ឆ្នាំ ២០១១-២០១៣

រៀបចំដោយ :

ឧបត្ថម្ភការបោះពុម្ពដោយ

unicef    Save the Children

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០១ . សលទ

**សារលិខិត**
**របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

- *សូមក្រាបថ្វាយបង្គំ សម្តេចព្រះសង្ឃរាជ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ !*
- *បងប្អូនជនរួមជាតិជាទីស្នេហា !*

ព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារ នៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២។ ការផ្តល់សច្ចាប័ននេះមានន័យថា ព្រះរាជាណាចក្រកម្ពុជាបានប្តេជ្ញាចិត្តជាផ្លូវការត្រូវតែគោរពសិទ្ធិកុមារ និងចាត់វិធានការនានា ដើម្បីប្រែក្លាយខ្លឹមសារអនុសញ្ញានេះឱ្យទៅជាការអនុវត្តជាក់ស្តែង។ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកថា **កុមារជាអនាគតរបស់ប្រទេសជាតិ** ។

ផ្តើមចេញពីនេះ ដើម្បីឱ្យកុមារគ្រប់រូបទទួលបាននូវសិទ្ធិពេញលេញ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវកម្មវិធីនយោបាយប្រយុទ្ធប្រឆាំងនឹងការរំលោភបំពានលើកុមារតាមគ្រប់រូបភាព ធានា ការពារ និងលើកស្ទួយសិទ្ធិជាមូលដ្ឋានទាំង ០៤របស់កុមារ ពង្រឹងការងារសុខុមាលភាពកុមារ ដើម្បីឱ្យកុមាររស់នៅក្នុងភាពថ្លៃថ្នូរ ប្រកបដោយសុវត្ថិភាព ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងឋានៈជាប្រធានកិត្តិយស នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ខ្ញុំសូមថ្លែងអំណរគុណចំពោះសមាជិក សមាជិកាក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារទាំងអស់ ដែលបានខិតខំរៀបចំផែនការយុទ្ធសាស្ត្ររយៈពេល ៣ឆ្នាំ (២០១១-២០១៣) នេះ ។

រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងខិតខំយ៉ាងសកម្មក្នុងកិច្ចការស្តារ និងអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច បង្កើនល្បឿនកំណែទម្រង់រដ្ឋលើវិស័យសំខាន់ៗ ដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកស្ទួយសុខុមាលភាពកុមារឱ្យបានល្អប្រសើរឡើង។ ដើម្បីសម្រេចគោលដៅនេះ ខ្ញុំសូមស្នើដល់គ្រប់ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ទាំងអស់ ដាក់បញ្ចូលបញ្ហាកុមារទៅក្នុងផែនការវិនិយោគ និងអភិវឌ្ឍន៍តាម វិស័យនានា ដោយចាត់ទុកថាការអភិវឌ្ឍពុំអាចកាត់ផ្តាច់ពីកុមារបានឡើយ ។

ខ្ញុំសូមអំពាវនាវដល់គ្រប់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ ព្រមទាំងបងប្អូនរួមជាតិទាំងអស់ សូមផ្តល់ការគាំទ្រ និងបន្តសហការជាមួយ

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ប្រែក្លាយផែនការយុទ្ធសាស្ត្រនេះ ឱ្យទៅជាសកម្មភាពជាក់ស្តែង និងចូលរួមក្នុងការដោះស្រាយបញ្ហា ដែលកំពុងតែកើតមានឡើងចំពោះកុមារ សំដៅជំរុញ និងលើកកម្ពស់ការអនុវត្តសិទ្ធិកុមារឱ្យកាន់តែល្អប្រសើរឡើង ដើម្បីបម្រើឧត្តមប្រយោជន៍របស់កុមារនៅកម្ពុជា ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ កុម្ភៈ ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# សេចក្តីថ្លែងអំណរគុណ

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកដែលបានចូលរួមផ្តល់បទសម្ភាសន៍ និងអ្នកដែលបានចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ទាំងអស់ ដែលបានខិតខំប្រឹងប្រែងផ្តល់ព័ត៌មានក្នុងការរៀបចំផែនការយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ រយៈពេល ៣ ឆ្នាំ (ឆ្នាំ ២០១១-២០១៣) មានដូចជា តំណាង ក្រសួង ស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានផ្តល់ពេលវេលាដ៏មានតម្លៃសម្រាប់ការផ្តល់បទសម្ភាសន៍ ក្នុងនោះមានដូចជា ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្ម ពលកម្មលើមនុស្ស (ក្រសួងមហាផ្ទៃ) ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងយុត្តិធម៌ ក្រសួងកិច្ចការនារី សមាគមជាតិកាកបាទក្រហមកម្ពុជា និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពង់ស្ពឺ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកណ្តាល ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាល មានដូចជា ចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ អង្គការយូនីសេហ្វ អង្គការសង្គ្រោះកុមារ គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ និងអង្គការអ៊ិកផាតកម្ពុជា ។

សូមថ្លែងអំណរគុណចំពោះអង្គការសង្គ្រោះកុមារដែលបានឧបត្ថម្ភគាំទ្រថវិកា និងបច្ចេកទេស ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រនេះ និងថ្លែងអំណរគុណចំពោះការចូលរួមរបស់កុមារ និងយុវជនទាំងអស់ ដែលបានផ្តល់ទស្សនៈដ៏មានតម្លៃនៅក្នុងដំណាក់កាលពិគ្រោះយោបល់ ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ជាសមាជិក សមាជិកានៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមពិនិត្យ និងផ្តល់យោបល់លើផែនការយុទ្ធសាស្ត្រនេះ។

សូមសម្តែងការកោតសរសើរដល់មន្ត្រីអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងដៃគូអភិវឌ្ឍទាំងអស់ដែលបានជួយជ្រោមជ្រែង និងផ្តល់គំនិតផ្តួចផ្តើមរៀបចំផែនការយុទ្ធសាស្ត្ររយៈពេល ៣ ឆ្នាំ ២០១១-២០១៣ នេះ ។

ជាចុងក្រោយ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងសូមកោតសរសើរចំពោះក្រុមការងារដែលបានខិតខំយកអស់កម្លាំងកាយ ចិត្ត ក្នុងការបំពេញការងារផ្នែកសិទ្ធិកុមារ ក្នុងប្រទេសកម្ពុជា។

# អារម្ភកថា

ផែនការយុទ្ធសាស្ត្ររយៈពេល ៣ ឆ្នាំ (២០១១-២០១៣) របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គឺជាផែនការយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ រៀបចំឡើងដោយអនុលោមតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ របស់រាជរដ្ឋាភិបាលកម្ពុជា និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងជាប្រធានកិត្តិយសនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្នុងគោលបំណងឆ្លើយតបទៅនឹងសកម្មភាពជាក់ស្តែងនាពេលបច្ចុប្បន្ន ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ខ្ពស់ចំពោះកុមារ និងធានាថាពួកគេទទួលបាននូវសិទ្ធិជាមូលដ្ឋាន ការវិនិយោគសមស្របជាធនធានមនុស្សសម្រាប់កសាងប្រទេសជាតិទៅអនាគត។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដែលជាយន្តការសម្របសម្រួល និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលលើការងារទាក់ទងនឹងការរស់រានមានជីវិត ការអភិវឌ្ឍ ការការពារ ការលើកកម្ពស់សុខុមាលភាព និងការចូលរួមចំណែករបស់កុមារ បានរៀបចំផែនការយុទ្ធសាស្ត្រនេះ ដោយឆ្លងកាត់ការពិភាក្សាពិគ្រោះយោបល់ជាច្រើនដំណាក់កាលជាមួយភាគីពាក់ព័ន្ធជាច្រើន ក្នុងនោះរួមមាន សមាជិកក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនៅតាមបណ្តាក្រសួងគន្លឹះ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ ខេត្តកណ្តាល និងកំពង់ស្ពឺ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ផងដែរ។ ផែនការយុទ្ធសាស្ត្រនេះនឹងនាំឱ្យការងារកុមារទាំងនៅថ្នាក់ជាតិ រាជធានី ខេត្ត និងនៅតាមក្រសួង ស្ថាប័ន ពិតជាមានការរីកចម្រើននិងប្រកបដោយចីរភាពតាមរយៈចក្ខុវិស័យ គោលដៅយុទ្ធសាស្ត្រ និងសកម្មភាពចម្បងសម្រាប់រយៈពេល ៣ ឆ្នាំ ខាងមុខ ដែលផ្តោតទៅលើការធ្វើឱ្យប្រសើរឡើងវិស័យអប់រំ សង្គមកិច្ច និងសុខាភិបាល ការគ្រប់គ្រងបែបវិមជ្ឈការនិងវិសហមជ្ឈការ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ។

សូមថ្លែងអំណរគុណចំពោះសមាជិក សមាជិកាក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ តំណាងក្រសួង ស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាលដែលបានចំណាយពេលវេលាដ៏មានតម្លៃពិនិត្យ និងផ្តល់យោបល់លើផែនការយុទ្ធសាស្ត្រនេះ និងសូមថ្លែងអំណរគុណចំពោះអង្គការសង្គ្រោះកុមារ ដែលឧបត្ថម្ភគាំទ្រចំពោះការរៀបចំផែនការយុទ្ធសាស្ត្រនេះ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០១១*

**ជ.ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

**ប្រធាន**

**អ៊ិត សំហេង**

# មាតិកា


ទំព័រ

សារលិខិតរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សេចក្ដីថ្លែងអំណរគុណ

អារម្ភកថា

មាតិកា

សេចក្ដីផ្ដើម ១

ផ្នែកទី ១ : គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់សិទ្ធិកុមារ ១

- ១.១- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១
- ១.២- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ១
- ១.៣- គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ២
- ១.៤- កត្តាប្រឈមក្នុងការលើកកម្ពស់សិទ្ធិកុមារ ៣

ផ្នែកទី ២ : ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ៣

- ២.១- សាវតារ ៣
- ២.២- តួនាទី ភារកិច្ច និងការប្រព្រឹត្តទៅរបស់ ក.ជ.ក. ៤
- ២.៣- តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក. ៦
- ២.៤- ពេលវេលាសម្រាប់ធ្វើរបាយការណ៍របស់ ក.ជ.ក. ជូនគណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ៧
- ២.៥- ការវិភាគចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងឧបសគ្គ ព្រមទាំងការកំណត់កាប្រឈមនិងសកម្មភាពដែលស្នើឡើង ៩

ផ្នែកទី ៣ : ដំណើរការរៀបចំផែនការយុទ្ធសាស្ត្ររបស់ ក.ជ.ក. ១៤

ផ្នែកទី ៤ : ការពិពណ៌នាអំពីផែនការសកម្មភាព ១៥

- ៤.១- ចក្ខុវិស័យ បេសកកម្ម ទិសដៅ និងគុណតម្លៃ ១៥
- ៤.២- ការកំណត់ទិសដៅ ១៦
- ៤.៣- គោលដៅយុទ្ធសាស្ត្រ គោលបំណង និងសកម្មភាពរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក. ១៦

ឧបសម្ព័ន្ធទី១ : អង្គការលេខរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ២៤

ឧបសម្ព័ន្ធទី២ : អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក. ២៥

ឧបសម្ព័ន្ធទី៣ : សេចក្ដីសង្ខេបការវិភាគ SWOT ២៦

ឧបសម្ព័ន្ធទី៤ : ផែនការសកម្មភាព ២៨


~~~~~~~~~~~~~~~
~~~~~~~~~~~~~~~

# សេចក្តីផ្តើម

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២ ។ យោងតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសមាត្រា៤៤ រាជរដ្ឋាភិបាលបានបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.) នៅឆ្នាំ១៩៩៥ ដើម្បីជាយន្តការសម្របសម្រួល និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលលើការងារទាក់ទងនឹងការរស់រានមានជីវិត ការអភិវឌ្ឍ ការការពារ ការលើកកម្ពស់សុខុមាលភាព និងការរួមចំណែករបស់កុមារ ។ នៅឆ្នាំ២០០៩ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានធ្វើការកែសម្រួលសមាសភាព និងរចនាសម្ព័ន្ធឡើងវិញ ដែលរចនាសម្ព័ន្ធថ្មីមានរហូតដល់រាជធានី ខេត្ត និងក្រុមការងារដើម្បីកុមារនៅតាមក្រសួង ស្ថាប័ន។ ការកែសម្រួលរចនាសម្ព័ន្ធនេះ មានគោលបំណងដើម្បីឱ្យស្របនឹងស្ថានភាពរីកចម្រើននៃការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនៅកម្ពុជា ។

ផែនការយុទ្ធសាស្ត្ររយៈពេល ៣ ឆ្នាំ ២០១១-២០១៣ បានរៀបចំដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងបានបញ្ជាក់ច្បាស់អំពីតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ អំពីសកម្មភាព និងរចនាសម្ព័ន្ធថ្មី ដូចមានចែងក្នុងព្រះរាជក្រឹត្យ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ឆ្នាំ២០០៩ និងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ឆ្នាំ២០១០។

# ផ្នែកទី១

## គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់សិទ្ធិកុមារ

### ១.១- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៤៨ចែងថា *"រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិរស់រានមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ ។ រដ្ឋគាំពារប្រឆាំងការងារទាំងឡាយណាដែលធ្វើអោយខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬ ដែលនាំឱ្យអន្តរាយដល់សុខភាព និងសុខុមាលភាពរបស់កុមារ "*។

កុមារគ្រប់រូបនៅក្នុងព្រះរាជាណាចក្រកម្ពុជាទទួលបានសិទ្ធិជាមូលដ្ឋានទាំងបួនរបស់ខ្លួន ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ជំនឿសាសនា ដើមកំណើត ជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។

### ១.២- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២

រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកកុមារជាទំពាំងស្នងឬស្សី និងជាអនាគតរបស់ប្រទេសជាតិ ស្របតាមយុទ្ធ-

សាស្ត្រចតុកោណដំណាក់កាលទី២ (ចតុកោណទី៤ មុំទី១: ការពង្រឹងគុណភាពវិស័យអប់រំ និងមុំទី២: ការលើកកម្ពស់សេវាសុខាភិបាល)

- ការពង្រឹងគុណភាពវិស័យអប់រំ : រាជរដ្ឋាភិបាលបានជំរុញឱ្យវិស័យអប់រំមានការរីកចម្រើនតាមយុទ្ធសាស្ត្រដំណាក់កាលទី២ ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ កម្មវិធីគាំទ្រវិស័យអប់រំ និងគោលដៅអប់រំសម្រាប់ទាំងអស់គ្នាក្នុងក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។
- ការលើកកម្ពស់សេវាសុខាភិបាល : រាជរដ្ឋាភិបាលបានលើកស្ទួយផ្នែកសុខភាពមាតា និងទារក ហើយចាត់ទុកកិច្ចការនេះ ជាកិច្ចការចម្បង និងអាទិភាពដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។

## ១.៣- គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា

រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើសេចក្តីប្រកាសសហស្សវត្សរ៍ និងបានប្តេជ្ញាចិត្តចំពោះការធ្វើឱ្យសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។ រាជរដ្ឋាភិបាលកម្ពុជាមានបំណងវាស់វែងនូវការអនុវត្តជាក់ស្តែងនៃការអភិវឌ្ឍរបស់ជាតិ ដោយអនុលោមតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងដើម្បីរៀបចំនូវរបាយការណ៍ស្តីពីភាពជឿនលឿននៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាឱ្យបានជាទៀងទាត់ ។

ប្រទេសកម្ពុជាបានធ្វើឱ្យមានការរីកចម្រើន ឆ្ពោះទៅសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ហើយនិងត្រូវមានការខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងទសវត្សរ៍បន្ត ។ ចាប់តាំងពីឆ្នាំ១៩៩៩មក ប្រទេសកម្ពុជាបានធ្វើឱ្យមានការរីកចម្រើនសំខាន់ៗជាច្រើននៅក្នុងការអនុវត្តក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចដែលមានទិសដៅសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចយូរអង្វែងនិងការអភិវឌ្ឍប្រកបដោយចីរភាព ។ ប្រទេសកម្ពុជាបានបោះជំហានទៅមុខគួរឱ្យកត់សម្គាល់សំដៅពង្រឹងស្ថិរភាពនយោបាយ និងសេដ្ឋកិច្ចក្នុងតំបន់។ ការគ្រប់គ្រងសេដ្ឋកិច្ចដែលមានលក្ខណៈសមស្រប ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ច គឺជាតម្រូវការចាំបាច់សម្រាប់ការកាត់បន្ថយភាពក្រីក្រប្រកបដោយចីរភាព និងសម្រាប់ឱ្យប្រទេសកម្ពុជាសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់ខ្លួន ។

គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាដែលពាក់ព័ន្ធនឹងកុមារ មានដូចខាងក្រោម :

គោលដៅទី១ : លុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លានធ្ងន់ធ្ងរ

គោលដៅទី២ : សម្រេចបានសកលកម្មការអប់រំបឋមសិក្សា

គោលដៅទី៤ : កាត់បន្ថយមរណភាពកុមារ

គោលដៅទី៥ : កែលម្អសុខភាពមាតា

គោលដៅទី៦ : ប្រយុទ្ធនឹងមេរោគអេដស៍ ជំងឺអេដស៍ គ្រុនចាញ់ និងជំងឺផ្សេងៗទៀត

គោលដៅទី៩ : ការដោះមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការសង្គ្រោះជនរងគ្រោះ ។

## ១.៤- គន្លារប្រឈមក្នុងការលើកកម្ពស់សិទ្ធិកុមារ

ការលើកកម្ពស់សិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ។ ទោះបីយ៉ាងណាក៏ដោយក៏នៅមានកុមារមួយចំនួនប្រឈមនឹងបញ្ហាជាច្រើនដូចជា : អំពើជួញដូរកុមារ កុមារទំនាស់នឹងច្បាប់ បញ្ហាគ្រឿងញៀន អំពើហិង្សាលើកុមារ ពលកម្មកុមារ ជំងឺដង្កាត់ផ្សេងៗ ភាពក្រីក្រ និងគុណភាពអប់រំ ជាដើម ។

# ផ្នែកទី២

# ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

## ២.១- សាវតារ

រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.ក) តាមអនុក្រឹត្យលេខ៨៣ អនប្រ.បក ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ បន្ទាប់មកនៅឆ្នាំ ១៩៩៩ ក.ជ.ក.ក បានធ្វើការកែសម្រួលមកអនុក្រឹត្យលេខ ៥៦ អនប្រ.បក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៩ និងនៅចុងឆ្នាំ២០០៩ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានធ្វើការកែសម្រួលមកជាព្រះរាជក្រឹត្យលេខ នស/រតក/១២០៩/១២០១ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលសរសេរអក្សរកាត់ថា ក.ជ.ក.។ ក.ជ.ក. ជាយន្តការសម្របសម្រួល និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលលើការងារទាក់ទងនឹងការរស់រានមានជីវិត ការអភិវឌ្ឍ ការការពារ ការលើកកម្ពស់សុខុមាលភាព និងការចូលរួមចំណែករបស់កុមារ។ តាមព្រះរាជក្រឹត្យថ្មីនេះ ក.ជ.ក. មានរចនាសម្ព័ន្ធរហូតដល់រាជធានី ខេត្ត និងក្រុមការងារដើម្បីកុមារនៅតាមក្រសួងស្ថាប័ន។

ក.ជ.ក.មានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| - សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី | | ប្រធានកិត្តិយស |
| - រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងកិច្ចការនារី | ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល | ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១រូប | អនុប្រធាន |
| - អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងការពារជាតិ | ១រូប | សមាជិក ៤ |

- អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងផែនការ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្មរ៉ែនិងថាមពល ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន ១រូប សមាជិក
- អនុរដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា ១រូប សមាជិក
- តំណាងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ១រូប សមាជិក
- តំណាងសមាគមជាតិកាកបាទក្រហមកម្ពុជា ១រូប សមាជិក
- តំណាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ១រូប សមាជិក
- តំណាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ១រូប សមាជិក
- អគ្គលេខាធិការ ក.ជ.ក. សមាជិកអចិន្ត្រៃយ៍ ។

## ២.២- តួនាទី ភារកិច្ច និងការប្រព្រឹត្តទៅរបស់ ក.ជ.ក.

### ក. តួនាទី និងភារកិច្ច

ក.ជ.ក. មានតួនាទី និងភារកិច្ចដូចតទៅ :

- ពិគ្រោះយោបល់ សម្របសម្រួលសកម្មភាពទាំងឡាយដែលពាក់ព័ន្ធទៅនឹងបញ្ហាកុមារ
- ពិនិត្យ តាមដាន វាយតម្លៃ លើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ កម្មវិធីជាតិសម្រាប់កុមារនៅកម្ពុជា និងលើកសំណើជូនរាជរដ្ឋាភិបាលអំពីតម្រូវការ និងបញ្ហាទាំងឡាយដែលធានាឧត្តមប្រយោជន៍របស់កុមារ
- ចូលរួមពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងកុមារ និងផ្តល់អនុសាសន៍ស្របនឹងអនុសញ្ញា និងបទដ្ឋានអន្តរជាតិផ្សេងៗស្តីពីកុមារ។

- ធ្វើការផ្សព្វផ្សាយច្បាប់ អនុសញ្ញាស្តីពីសិទ្ធិកុមារ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងបញ្ហានានារបស់កុមារ និងបំផុសចលនាគាំទ្រការអនុវត្តសិទ្ធិកុមារឱ្យមានប្រសិទ្ធភាព
- រៀបចំគោលនយោបាយ ផែនការ កម្មវិធី និងសកម្មភាពផ្សេងៗ ដើម្បីឧត្តមប្រយោជន៍ដល់កុមារមានជាអាទិ៍ ការគោរពនិងការអនុវត្តសិទ្ធិកុមារ ការរស់រានមានជីវិត ការអភិវឌ្ឍ ការការពារ ការលើកកម្ពស់សុខុមាលភាព ការចូលរួមចំណែករបស់កុមារ ការប្រឆាំងនឹងអំពើហិង្សា ការទប់ស្កាត់ ការលុបបំបាត់ការកេងប្រវ័ញ្ចគ្រប់រូបភាពមកលើកុមារ និងការប្រឆាំងការជួញដូរគ្រឿងញៀន
- ធ្វើទំនាក់ទំនងជាមួយសហគមន៍ជាតិ អន្តរជាតិ ដែលមានការងារប្រហាក់ប្រហែលគ្នា ដើម្បីរកជំនួយឧបត្ថម្ភ និងផ្លាស់ប្តូរព័ត៌មាន និងបទពិសោធន៍ និងទស្សនៈវិកចម្រើន ដែលទាក់ទងនឹងគោលដៅរួមក្នុងការកែលម្អស្ថានភាពកុមារ
- ស្រាវជ្រាវ និងជូនព័ត៌មានស្តីអំពីសេចក្តីត្រូវការនិងបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងកុមារកម្ពុជា ជូនរាជរដ្ឋាភិបាល ស្ថាប័ន និងអង្គការនានាដែលមានសមត្ថកិច្ច
- ពិនិត្យ និងសម្រេចបទបញ្ជាផ្ទៃក្នុងរបស់ ក.ជ.ក.
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាអន្តរជាតិ ដែលពាក់ព័ន្ធនឹងសិទ្ធិរបស់កុមារ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

### ៩- ការប្រព្រឹត្តទៅរបស់ ក.ជ.ក.

ក.ជ.ក ត្រូវជួបប្រជុំយ៉ាងតិច ២ (ពីរ) ដងក្នុងមួយឆ្នាំ។ ក្នុងករណីចាំបាច់ ក.ជ.ក. អាចប្រជុំជាវិសាមញ្ញបានតាមការអញ្ជើញរបស់ប្រធាន ។

ក្នុងមួយឆ្នាំម្តង ក.ជ.ក. ត្រូវធ្វើការបូកសរុបរបាយការណ៍ អំពីលទ្ធផលនៃការអនុវត្តកម្មវិធីការងារ និងអនុសាសន៍ដែល ក.ជ.ក. ត្រូវដាក់ជូនរាជរដ្ឋាភិបាល។

ក.ជ.ក. មានសិទ្ធិទាក់ទងនិងអញ្ជើញក្រសួង ស្ថាប័នពាក់ព័ន្ធនានា តំណាងកុមារ អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍ ដើម្បីចូលរួមប្រជុំផ្តល់យោបល់ ឬធ្វើជាអ្នកសង្កេតការណ៍។

របៀបរបបនៃការប្រជុំរបស់ ក.ជ.ក. ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ ក.ជ.ក.។

ក.ជ.ក. មានសិទ្ធិប្រើប្រាស់ត្រាដោយឡែករបស់ខ្លួន ដើម្បីបំពេញការងារ។

ក.ជ.ក. មានអគ្គលេខាធិការដ្ឋានមួយជាអង្គភាពប្រតិបត្តិ ដែលមានទីតាំងនៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

អគ្គលេខាធិការដ្ឋាន ក.ជ.ក. ដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនដែលតែងតាំងដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក. ត្រូវកំណត់ដោយអនុក្រឹត្យ ។ល

ក.ជ.ក. អាចបង្កើតគណៈកម្មការឬអនុគណៈកម្មការជំនាញមួយចំនួនតាមការចាំបាច់ ដែលសមាសភាពដឹកនាំរបស់គណៈកម្មការឬអនុគណៈកម្មការនីមួយៗ ត្រូវជ្រើសរើសពីសមាជិកនៃ ក.ជ.ក. និងដែលមានមន្ត្រីជំនាញ របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ តំណាងកុមារ អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍចូលរួមជាសមាជិក។

សមាសភាព តួនាទី និងភារកិច្ចរបស់គណៈកម្មការឬអនុគណៈកម្មការជំនាញ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន ក.ជ.ក.។

ក.ជ.ក. អាចទទួលយកទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិឬអ្នកជំនាញការអន្តរជាតិមួយចំនួនតាមការចាំបាច់ ដើម្បីជួយការងារ ក.ជ.ក. និងអគ្គលេខាធិការដ្ឋាន។

ក.ជ.ក. ត្រូវបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ថ្នាក់រាជធានី ខេត្ត និងបង្កើតក្រុមការងារដើម្បីកុមារនៅតាមក្រសួង ស្ថាប័ននីមួយៗ។

សមាសភាព តួនាទី ភារកិច្ច និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ថ្នាក់រាជធានី ខេត្ត និង បង្កើតក្រុមការងារដើម្បីកុមារ នៅតាមក្រសួង ស្ថាប័ន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន ក.ជ.ក.។

អង្គការលេខរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ មានបង្ហាញជូននៅក្នុងឧបសម្ព័ន្ធទី១។

## ២.៣- តួនាទី ភារកិច្ច និងមេធាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក.

### ក. តួនាទី និងភារកិច្ច

អគ្គលេខាធិការដ្ឋាន ក.ជ.ក. មានតួនាទី និងភារកិច្ចដូចតទៅ :

- រៀបចំ និងអនុវត្តផែនការសកម្មភាពការងារពាក់ព័ន្ធនឹងកុមារ រយៈពេលខ្លី មធ្យម និងវែង
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ពិធីសារនានាដែលពាក់ព័ន្ធនឹងកុមារ និងកម្មវិធីជាតិដាក់ជូន ក.ជ.ក.
- ពិនិត្យតាមដានស្ថានភាពរបស់កុមារ និងផ្តល់អនុសាសន៍ ដោយផ្អែកលើគោលនយោបាយជាតិរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ
- ជំរុញការផ្សព្វផ្សាយខ្លឹមសារអនុសញ្ញាស្តីពីសិទ្ធិកុមារ ឱ្យបានទូលំទូលាយរហូតដល់ថ្នាក់ក្រោមជាតិ
- សិក្សាស្រាវជ្រាវច្បាប់ជាតិ អន្តរជាតិ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងកុមារ ដើម្បីតាមដានវាយតម្លៃ និងលើកអនុសាសន៍ជូន ក.ជ.ក.
- ធ្វើសហប្រតិបត្តិការនិងសហការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ តំណាងកុមារ អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍដើម្បីលើកអនុសាសន៍ជូន ក.ជ.ក. ពិនិត្យសម្រេច និងធ្វើជូនរាជរដ្ឋាភិបាល
- ធានានិរន្តរភាព និងដំណើរការរដ្ឋបាលរបស់ ក.ជ.ក. និងគ្រប់គ្រងមន្ត្រីអគ្គលេខាធិការដ្ឋាន ក.ជ.ក.
- លើកសំណើតែងតាំង ផ្ទេរភារកិច្ច បញ្ឈប់ពីតំណែង និងជ្រើសរើសមន្ត្រីរាជការដែលមានក្របខ័ណ្ឌ

ស្រាប់ និងមន្ត្រីជាប់កិច្ចសន្យាក្នុងអគ្គលេខាធិការដ្ឋានជូនប្រធាន ក.ជ.ក.

- លើកគម្រោងថវិកាប្រចាំឆ្នាំសម្រាប់កិច្ចដំណើរការ ក.ជ.ក.
- គ្រប់គ្រងថវិកា និងធ្វើបញ្ជីសារពើភណ្ឌចលនទ្រព្យ និងអចលនទ្រព្យរបស់ ក.ជ.ក.
- រៀបចំសិក្ខាសាលា និងកិច្ចប្រជុំផ្សេងៗរបស់ ក.ជ.ក.
- ចងក្រងព័ត៌មាន និងឯកសារទាំងអស់ដែលពាក់ព័ន្ធទៅនឹងកុមារ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ស្តីពីសកម្មភាពការងាររបស់ ក.ជ.ក.
- បំពេញភារកិច្ចផ្សេងៗទៀត ដែលប្រធាន ក.ជ.ក. ប្រគល់ជូន ។

### ៩. រចនាសម្ព័ន្ធ

អគ្គលេខាធិការដ្ឋាន ក.ជ.ក. មានរចនាសម្ព័ន្ធដូចតទៅ :

- ផ្នែករដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- ផ្នែកការការពារកុមារនិងពិនិត្យតាមដាន
- ផ្នែកអប់រំ ផ្សព្វផ្សាយ និងអភិវឌ្ឍន៍ធនធានមនុស្ស

ផ្នែកនីមួយៗត្រូវដឹកនាំដោយប្រធានផ្នែកមួយរូប អមដោយអនុប្រធានផ្នែកមួយចំនួនជាជំនួយការតាមការចាំបាច់ ។

ប្រធានផ្នែកមានឋានៈស្មើប្រធាននាយកដ្ឋាន អនុប្រធានផ្នែកមានឋានៈស្មើអនុប្រធាននាយកដ្ឋាន ។

ផ្នែកនីមួយៗមានការិយាល័យចំណុះតាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះផ្នែកនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដែលជាប្រធាន ក.ជ.ក. ។

អគ្គលេខាធិការដ្ឋាន ក.ជ.ក. មានមន្ត្រីបម្រើការងារមកពីក្របខ័ណ្ឌមុខងារសាធារណៈ ។ ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋាន អាចមានមន្ត្រីជាប់កិច្ចសន្យាដើម្បីជួយបំពេញការងារ ។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ មានបង្ហាញជូននៅក្នុងឧបសម្ព័ន្ធទី២ ។

## ២.៤- ពេលវេលាសម្រាប់ការរៀបចំរបាយការណ៍របស់ ក.ជ.ក. ជូនគណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិ

មាត្រា ៤៤ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារចែងថា រដ្ឋជាភាគីត្រូវរៀបចំរបាយការណ៍ជូនគណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ អំពីលទ្ធផលនៃការអនុវត្តសិទ្ធិកុមារនៅក្នុងរយៈពេល២ឆ្នាំ បន្ទាប់ពីការផ្តល់សច្ចាប័ន និងរៀងរាល់៥ឆ្នាំម្តង ។ ខាងក្រោមនេះជាតារាងបង្ហាញពេលវេលា ដែលប្រទេសកម្ពុជាត្រូវរៀបចំរបាយ៖

ការណ៍ចាប់តាំងពីចូលជាសមាជិកនៃអនុសញ្ញា រហូតមកដល់ពេលបច្ចុប្បន្ននេះ ៖

| | |
|---|---|
| ខែតុលា ឆ្នាំ១៩៩២ | កម្ពុជាបានផ្តល់សច្ចាប័នអនុសញ្ញាស្តីពីសិទ្ធិកុមារ |
| ខែធ្នូ ឆ្នាំ១៩៩៧ | រាជរដ្ឋាភិបាលកម្ពុជាបានដាក់ជូនរបាយការណ៍ដំបូងទៅកាន់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ |
| ខែមិថុនា ឆ្នាំ២០០០ | គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ បានចេញនូវរបាយការណ៍សង្កេតមួយជូនរាជរដ្ឋាភិបាលកម្ពុជា |
| ខែឧសភា ឆ្នាំ២០០៤ | រាជរដ្ឋាភិបាលកម្ពុជា បានយល់ស្របតាមសេចក្តីសម្រេចចិត្តរបស់អង្គការសហប្រជាជាតិស្តីពី "ពិភពលោកសមស្របសម្រាប់កុមារ" ហើយក្នុងឆ្នាំ ២០០៤ រាជរដ្ឋាភិបាលបានចេញសេចក្តីប្រកាស "កម្ពុជាដើម្បីកុមារ" |
| ខែមីនា ឆ្នាំ២០០៩ | ក.ជ.ក. បានដាក់របាយការណ៍ទ្វេរទាត់លើកទី ២ និងលើកទី៣ ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនៅកម្ពុជា (២០០០-២០០៧) |
| ខែកក្កដា ឆ្នាំ២០១០ | ក.ជ.ក. បានរៀបចំរបាយការណ៍អនុវត្តសេចក្តីសម្រេចចិត្តលេខ ២០០៩/២៦ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចនៃអង្គការសហប្រជាជាតិស្តីពីការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងជាតិ និងអន្តរជាតិ ដើម្បីកំណែទម្រង់យុត្តិធម៌កុមារ និងបានផ្ញើជូនការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្មរបស់អង្គការសហប្រជាជាតិ |
| ចុងឆ្នាំ២០១០ | ក.ជ.ក. កំពុងរៀបចំរបាយការណ៍ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ និងការលក់កុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ |
| ឆ្នាំ ២០១១ | គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិនឹងដាក់សេចក្តីសង្កេតចំពោះរបាយការណ៍លើកទី ២ និងលើកទី ៣ |
| ឆ្នាំ ២០១២ | ក.ជ.ក. នឹងរៀបចំសេចក្តីព្រាងរបាយការណ៍លើកទី ៤ ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារនៅកម្ពុជា |

ទៅថ្ងៃអនាគត សកម្មភាពនៃការរៀបចំរបាយការណ៍ផ្ញើជូនគណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិ គឺជាចំណាប់អារម្មណ៍ពិសេសក្នុងអំឡុងពេល៣ឆ្នាំ នៃផែនការយុទ្ធសាស្ត្រនេះ គឺសេចក្តីសង្កេតពីគណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ចំពោះរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារលើកទី ២ និងលើកទី ៣ និងការផ្ញើជូននៅពេលខាងមុខនូវរបាយការណ៍ស្តីពីពិធីសារបន្ថែម ស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ និងពិធីសារបន្ថែមស្តីពីការលក់ដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ ។ ទន្ទឹមនឹងនេះដែរ សេចក្តីព្រាងរបាយការណ៍លើកទី ៤ ស្តីពីការអនុវត្តសិទ្ធិកុមារនៅកម្ពុជា នឹងចាប់ផ្តើមនៅក្នុង

ឆ្នាំ ២០១២ខាងមុខនេះ ជាពិសេស សេចក្តីសង្កេតចំពោះរបាយការណ៍លើកទី២ និងទី៣ នឹងកំណត់នូវអាទិភាពថ្មីៗសម្រាប់រាជរដ្ឋាភិបាលកម្ពុជាអនុវត្តពាក់ព័ន្ធនឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ និងសម្រាប់ ក.ជ.ក. ដែលជាស្ថាប័នសម្របសម្រួល។

ក.ជ.ក. មិនត្រឹមតែរៀបចំរបាយការណ៍ជូនគណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិប៉ុណ្ណោះទេ ថែមទាំងរៀបចំរបាយការណ៍ផ្សេងៗទៀតតាមការស្នើសុំរបស់តំបន់ ឬសកលលោកផងដែរ ដូចជា របាយការណ៍ស្តីពីអំពើហិង្សាលើកុមារ ឆ្នាំ២០០៥ របាយការណ៍ពិភពលោកសមស្របសម្រាប់កុមារ ឆ្នាំ២០០៦។ របាយការណ៍ស្តីពីការលក់សរីរាង្គកុមារ ឆ្នាំ២០០៧ របាយការណ៍ស្តីពីការលក់ដូរ ការជួញដូរផ្លូវភេទ និងរូបភាពអាសអាភាសកុមារ ឆ្នាំ២០០៧។

លើសពីនេះ ក្នុងរយៈពេលជាង ១០ ឆ្នាំចុងក្រោយនេះ សកម្មភាពរបស់ ក.ជ.ក. ក្នុងការរៀបចំរបាយការណ៍ផ្ញើជូនគណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ការរៀបចំព្រឹត្តិការណ៍ទាំងឡាយពាក់ព័ន្ធនឹងការជួញដូរ កេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងកេងប្រវ័ញ្ចកម្លាំងពលកម្មលើកុមារមានភាពកាន់តែសកម្ម។ ជាមួយគ្នានេះដែរ ក.ជ.ក. ក៏បានជួយដល់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌កុមារ និងបានផ្សព្វផ្សាយសិទ្ធិកុមារដល់អ្នកមានភារកិច្ចអនុវត្ត នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងផ្សព្វផ្សាយយ៉ាងទូលំទូលាយទៅដល់សហគមន៍។ ការសម្របសម្រួលរៀបចំទិវាកុមារអន្តរជាតិ ១ មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា បានរៀបចំជារៀងរាល់ឆ្នាំ។

## ២.៥- ការវិភាគចំណុចខ្លាំង ចំណុចខ្សោយ ឱកាសនិងឧបសគ្គ ព្រមទាំងការកំណត់បញ្ហាប្រឈម និងសកម្មភាពនានាដែលស្នើឡើង

ការវិភាគចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងឧបសគ្គ (SWOT) ត្រូវបានអនុវត្តបន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធសំខាន់ៗ ។ ការវិភាគមានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី៣ ហើយការវិភាគពីចំណុចខ្លាំង ចំណុចខ្សោយរបស់ ក.ជ.ក. បានផ្តល់ជាមូលដ្ឋានសម្រាប់បង្កើតនូវយុទ្ធសាស្ត្រដែលជាការកើតឡើងបន្ថែមពីលើចំណុចខ្លាំងនានាដែលបានកំណត់មក ព្រមទាំងកាត់បន្ថយឱ្យនៅជាអប្បបរមានូវប្រការនានាដែលកំពុងមានវត្តមានឡើង ថាជាបញ្ហាប្រឈមនោះ ឬក៏ជាប្រការដែលតម្រូវឱ្យមានការកែលម្អកាន់តែប្រសើរឡើងថែមទៀត។ ការវិភាគ SWOT នេះក៏បានធ្វើឱ្យ ក.ជ.ក. អាចមានសមត្ថភាពធ្វើការប៉ាន់ប្រមាណអំពីឱកាសជាសក្តានុពល និងឧបសគ្គពីខាងក្រៅ ព្រមទាំងឧបសគ្គនានាសម្រាប់ការធ្វើការបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រលើកទី១នេះ។

ការប្រឈម និងសកម្មភាពនានាដើម្បីជម្នះនូវបញ្ហាទាំងឡាយ ត្រូវបានកំណត់ដូចខាងក្រោមនេះ :

**គោលដៅយុទ្ធសាស្ត្រទី ១ ការសម្របសម្រួល សមត្ថភាព និងរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក.**

**ការប្រឈមទី ១ :** សមត្ថភាពរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក. នៅមានកម្រិត

- អនុវត្តនូវការវិភាគទៅលើតម្រូវការនានាផ្នែកបណ្តុះបណ្តាលនៃមន្រ្តីទាំងឡាយ កំណត់ឱ្យបានកម្មវិធីជំនាញនានាដែលត្រូវបណ្តុះបណ្តាលប្រភពនៃជំនាញថ្មីៗ ព្រមជាមួយជំនាញបច្ចេកទេសជាក់លាក់នានា (ឧ.ផ្នែកតស៊ូមតិ ផ្នែកបង្កើតគោលនយោបាយ ផ្នែកវិភាគ និងការរៀបចំរបាយការណ៍ ផ្នែកទំនាក់ទំនង ផ្នែករៃអង្គាសមូលនិធិ ផ្នែកដឹកនាំ និងគ្រប់គ្រង ឧបសគ្គផ្នែកភាសា តម្រូវការក្នុងការបកប្រែ) ។
- ពង្រឹង និងពង្រីករចនាសម្ព័ន្ធ សមត្ថភាពមន្រ្តី តួនាទី ការទទួលខុសត្រូវ និងថវិកាទ្រទ្រង់ ។
- រៀបចំថវិកាសម្រាប់ការអភិវឌ្ឍបច្ចេកទេសនៅក្នុងផែនការយុទ្ធសាស្រ្ត (ឧ.ប្រព័ន្ធទិន្នន័យ គេហទំព័រមជ្ឈមណ្ឌលធនធានបច្ចេកវិទ្យាព័ត៌មាន (ITRC) ។
- តស៊ូមតិដើម្បីទទួលបាននូវថវិកាជាក់លាក់ពីរាជរដ្ឋាភិបាលសម្រាប់ការចំណាយសំខាន់ៗរបស់ ក.ជ.ក. និងដើម្បីសម្របសម្រួលការផ្តួចផ្តើម និងសកម្មភាពរយៈពេលវែងទាំងឡាយ ។
- កំណត់ឱ្យបាននូវដៃគូអភិវឌ្ឍថ្មីៗដើម្បីឱ្យគេជួយឧបត្ថម្ភមូលនិធិ ឬបង្កើនធនធានមនុស្ស និងធនធានជារូបវ័ន្តរបស់ ក.ជ.ក. ។
- រៀបចំថវិកាសម្រាប់ដោះស្រាយតម្រូវការរយៈពេលខ្លី មធ្យម និងវែងឱ្យស្របជាមួយផែនការយុទ្ធសាស្រ្ត ។

**ការប្រឈមទី ២ :** កង្វះធនធានសម្រាប់កុមារក្នុងការរៀបចំផែនការរបស់រាជរដ្ឋាភិបាល ការរៀបចំថវិកាសង្គមកិច្ច

ធ្វើការតស៊ូមតិជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវធនធាន ថវិកាជាក់លាក់ ដើម្បីលើកកម្ពស់ការអនុវត្តឱ្យបានសម្រេចនូវសេវាសម្រាប់កុមារ និងការអនុវត្តពេញលេញនូវសិទ្ធិកុមារនៅបណ្តាក្រសួងទាំងឡាយ ។

**ការប្រឈមទី ៣ :** តម្រូវការឱ្យមានភាពច្បាស់លាស់អំពីតួនាទីរបស់ ក.ជ.ក. នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេស ពាក់ព័ន្ធជាមួយក្រុមការងារថ្មីនៅថ្នាក់ជាតិ (ក្រសួង ស្ថាប័ននានា) និងនៅថ្នាក់រាជធានីខេត្ត។ រចនាសម្ព័ន្ធអនុគណៈកម្មការដែលមានស្រាប់តម្រូវឱ្យមានការកែសម្រួល ឬបញ្ជាក់ឱ្យបានច្បាស់លាស់ ។

- ធ្វើការផ្សព្វផ្សាយព្រះរាជក្រឹត្យ អនុក្រឹត្យ និងផែនការយុទ្ធសាស្រ្តឱ្យបានទូលំទូលាយ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីតួនាទីរបស់ ក.ជ.ក. ។
- ធ្វើការវិភាគអំពីរចនាសម្ព័ន្ធ គណៈកម្មាធិការ ឬក្រុមការងារដែលមានស្រាប់នៅក្នុងបណ្តាក្រសួងស្ថាប័ន រាជធានី ខេត្ត ដើម្បីកំណត់អំពីទំនាក់ទំនង និងធានានូវភាពមិនជាន់គ្នាជាមួយក្រុមការងារថ្មី ឧ.ក្រុមការងារថ្នាក់ជាតិពហុវិស័យស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ ការជួញដូរកុមារ ។ល ។
- ធ្វើការផ្ទៀងផ្ទាត់ឡើងវិញអំពីកម្រិតនៃការធ្វើសេចក្តីសម្រេចចិត្តនៃផ្នែកទាំងឡាយដែលបានលើក៩

ខាងលើ។

- ធ្វើការពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធអនុគណៈកម្មាធិការដែលមានស្រាប់ ដោយហេតុថាមានអនុគណៈកម្មការខ្លះមាននៅក្នុងផ្នែកនានា ព្រមទាំងពង្រឹងយន្តការសម្របសម្រួលរបស់ ក.ជ.ក. ជាមួយអនុគណៈកម្មការទាំងនេះ។ កំណត់មន្ត្រីបច្ចេកទេសជាក់លាក់ ដើម្បីសម្របសម្រួលរវាងអនុគណៈកម្មការ និងលេខាធិការដ្ឋាន។
- ធ្វើការពង្រឹងយន្តការសម្របសម្រួលរបស់ ក.ជ.ក. នៅថ្នាក់រាជធានី ខេត្ត ដោយប្រើប្រាស់រចនាសម្ព័ន្ធដែលមានស្រាប់ចុះទៅដល់មូលដ្ឋាន ឧ.ធ្វើការផ្សារភ្ជាប់ជាមួយគណៈកម្មាធិការពិគ្រោះយោបល់អំពីស្ត្រីនិងកុមារ និងធានាឱ្យមានការធ្វើទំនាក់ទំនងគ្នានៅពេលអនាគតជាមួយគណៈកម្មាធិការថ្មីដែលមានលក្ខណៈស្រដៀងគ្នានៅថ្នាក់រាជធានី ខេត្ត និងស្រុកនៅពេលដែលគណៈកម្មាធិការទាំងនេះត្រូវបានបង្កើត។

**គោលដៅយុទ្ធសាស្ត្រទី ២ : ការលើកកម្ពស់ការយល់ដឹង និងការតស៊ូមតិដើម្បីសិទ្ធិកុមារ**

**ការប្រឈមទី ៤ :** ការយល់ដឹងអំពីសិទ្ធិកុមារក្នុងចំណោមអ្នកមានភារកិច្ចនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ថ្នាក់សហគមន៍ និងកុមារនៅមានកម្រិត

- ធ្វើការតស៊ូមតិជាមួយរាជរដ្ឋាភិបាលឱ្យកំណត់បញ្ហាសិទ្ធិកុមារ ជាអាទិភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅក្នុងផែនការ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។
- លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកុមារជាមួយរដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ ដោយផ្សព្វផ្សាយព័ត៌មាននៅថ្នាក់ខេត្ត ស្រុក និងយន្តការថ្នាក់ឃុំដោយសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល។
- លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកុមារដល់មាតាបិតា អាណាព្យាបាល និងកុមារ តាមរយៈការផ្សព្វផ្សាយព័ត៌មាននៅថ្នាក់សហគមន៍ និងគ្រួសារដោយសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល។
- ធានាឱ្យមានការផ្តល់ឱកាសនិងការគាំទ្រពីរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រាប់កុមារឱ្យបានចូលរួមនៅក្នុងក្លឹបឬក្រុមរបស់ខ្លួន ឬនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តនៅតាមគេហដ្ឋាន សហគមន៍ និងសាលារៀន ព្រមទាំងក្នុងសកម្មភាពលើកកម្ពស់ការយល់ដឹងនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ។
- សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងព័ត៌មាន ដើម្បីបញ្ជ្រាបសិទ្ធិកុមារចូលទៅក្នុងការប្រឡងប្រណាំងនៅតាមសាលារៀន និងចុះផ្សាយនៅក្នុងអត្ថបទសារព័ត៌មានជាទៀងទាត់។
- ធ្វើយុទ្ធនាការផ្សព្វផ្សាយជាទ្រង់ទ្រាយធំតាមប្រព័ន្ធផ្សព្វផ្សាយជាតិ ដើម្បីធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយហើយធ្វើនៅពេលវេលាសមស្របដល់កុមារ និងគ្រួសារ។
- រៀបចំព្រឹត្តិការណ៍លើកកម្ពស់ការយល់ដឹង និងតស៊ូមតិថ្នាក់ជាតិ ដូចជា ទិវាកុមារអន្តរជាតិ ទិវា-

ពិភពលោកប្រឆាំងពលកម្មកុមារ ជាដើម ។

- រៀបចំបង្កើតគេហទំព័ររបស់ ក.ជ.ក. និងមជ្ឈមណ្ឌលធនធានផ្នែកបច្ចេកវិទ្យាព័ត៌មាន (ITRC) ដើម្បីបង្កើនការយល់ដឹងអំពីតួនាទីរបស់ ក.ជ.ក. ដែលដើរតួនាទីជាកន្លែងផ្តល់ធនធាន និងឯកសារយោងសម្រាប់ការស្រាវជ្រាវរកព័ត៌មានទាក់ទងនឹងសិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា ។

**គោលដៅយុទ្ធសាស្ត្រទី ៣ : ការរៀបចំរបាយការណ៍ ការពិនិត្យតាមដាន និងការវាយតម្លៃលើការអនុវត្តសិទ្ធិកុមារ**

**ការប្រឈមទី ៥ :** កង្វះជំនាញរៀបចំរបាយការណ៍ដ៏ជាក់លាក់អំពីសិទ្ធិកុមារ

- កសាងសមត្ថភាពនៅក្នុងជំនាញបច្ចេកទេសដ៏ចាំបាច់សម្រាប់រៀបចំរបាយការណ៍ឱ្យស្របតាមតម្រូវការរបស់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ។
- កសាងសមត្ថភាពមន្ត្រីសំខាន់ៗនៅក្នុងការប្រមូលនិងវិភាគទិន្នន័យប្រកបដោយគុណភាព និងបរិមាណនៃទិន្នន័យ ដើម្បីអាចរៀបចំរបាយការណ៍ដែលមានលក្ខណៈសកម្មទុកជាមុន និងប្រកបដោយការពិចារណាល្អិតល្អន់ ។
- ធ្វើការរៀបចំគោលការណ៍ណែនាំអំពីដំណើរការនៃការរៀបចំរបាយការណ៍ជាភាសាខ្មែរ សម្រាប់សមាជិក ក.ជ.ក. ដើម្បីធ្វើការសិក្សា និងចូលរួមនៅក្នុងដំណើរការនេះ ។

**ការប្រឈមទី ៦ :** កង្វះយន្តការសម្រាប់ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តសិទ្ធិកុមារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- បង្កើតទំនាក់ទំនងផ្សារភ្ជាប់ជាមួយប្រភពដែលផ្តល់ទិន្នន័យសំខាន់ៗរបស់រាជរដ្ឋាភិបាល ដែលមានស្រាប់ ឧ. CamInfo, EYMS និងទិន្នន័យរបស់ក្រសួងសុខាភិបាល ។
- ធ្វើការវិភាគអំពីភាពខ្វះចន្លោះនៅក្នុងព័ត៌មានដែលអាចរកបាន សម្រាប់ធ្វើការពិនិត្យតាមដានសិទ្ធិកុមារ និងស្នើសុំការរៀបចំរបាយការណ៍ថ្មីៗប្រសិនបើចាំបាច់ ។
- បង្កើតបណ្តាញប្រមូលទិន្នន័យជាមួយប្រភពរាយការណ៍ថ្នាក់ក្រោមជាតិ ។
- បង្កើតប្រព័ន្ធទិន្នន័យផ្ទាល់ខ្លួនរបស់ខ្លួនទាក់ទងនឹងបញ្ហាសិទ្ធិកុមារ និងធ្វើការបណ្តុះបណ្តាលសមាជិកទាំងឡាយឱ្យចេះប្រើប្រាស់ប្រព័ន្ធនោះ ។
- កំណត់សូចនាករ ទម្រង់នៃរបាយការណ៍ និងនីតិវិធីនៃការរៀបចំរបាយការណ៍ជាមួយស្ថាប័នរៀបចំរបាយការណ៍នានា ។
- ធ្វើការជាមួយក្រសួងផែនការដើម្បីបញ្ជ្រាបរបាយការណ៍ និងការអនុវត្តអំពីសិទ្ធិកុមារចូលទៅក្នុងការធ្វើផែនការថ្នាក់ជាតិ (ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ) ផែនការតាមវិស័យ និងការធ្វើផែនការថ្នាក់ក្រោមជាតិ ។

- ប្រើប្រាស់ក្រុមការងាររបស់ ក.ជ.ក. អនុគណៈកម្មការ និង ក.ជ.ក. ថ្នាក់ខេត្តដើម្បីវាយការណ៍អំពីលំហូរនៃទិន្នន័យពីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងធ្វើការកែលម្អតាមការចាំបាច់។ រៀបចំបទដ្ឋានជាក់ស្តែងសម្រាប់ក្រសួងពាក់ព័ន្ធអំពីវិធីប្រមូលព័ត៌មាន និងរៀបចំឱ្យមានការពិភាក្សាជាមួយកុមារ ដើម្បីធានាឱ្យមានការចូលរួមរបស់កុមារប្រកបដោយអត្ថន័យ។

## គោលដៅយុទ្ធសាស្ត្រទី ៤ : ច្បាប់ និងគោលនយោបាយសម្រាប់កុមារ

**ការប្រឈមទី ៧ :** ច្បាប់ និងគោលនយោបាយបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជាតម្រូវឱ្យមានការវិភាគដើម្បីធានាអំពីបទដ្ឋានអន្តរជាតិ ជាតិ និងធ្វើការរៀបចំច្បាប់ គោលនយោបាយ និងផែនការសកម្មភាពជាតិថ្មីៗ

- ធ្វើការពិនិត្យឡើងវិញនូវច្បាប់ជាតិ អន្តរជាតិ និងគោលការណ៍ពាក់ព័ន្ធនឹងសិទ្ធិកុមារបច្ចុប្បន្ន (ដែលនឹងចាប់ផ្តើមនៅដើមឆ្នាំ ២០១១)។ បញ្ហាដែលត្រូវស្រាវជ្រាវរក រួមមាន ច្បាប់ការពារកុមារ ច្បាប់ពាក់ព័ន្ធកេរមរតក ការបង្កើតតុលាការកុមារ ផែនការសកម្មភាពជាតិសម្រាប់កុមារ ច្បាប់ការងារទាក់ទងនឹងកុមារ។
- ពិនិត្យ និងផ្តល់អនុសាសន៍ជូនរដ្ឋាភិបាលចំពោះច្បាប់ និងកម្មវិធីសកម្មភាពជាតិនានា ដូចដែលកំណត់ខាងលើ។
- ធ្វើសេចក្តីព្រាងច្បាប់ និងគោលនយោបាយស្តីពីសិទ្ធិកុមារថ្មីៗ និងផែនការសកម្មភាពជាតិថ្មីៗ ឧ. ផែនការសកម្មភាពជាតិសម្រាប់កុមារ ច្បាប់ពាក់ព័ន្ធកេរមរតក ការបង្កើតតុលាការកុមារ គោលនយោបាយជាតិតែមួយស្តីពីកុមារ។
- ធ្វើការពិគ្រោះយោបល់ដើម្បីធានាថា ច្បាប់ និងគោលនយោបាយទាំងឡាយមានបញ្ចូល ដូចជាបញ្ហាយេនឌ័រ ពិការភាព និងជាតិពន្ធុ។
- ធ្វើការពិគ្រោះយោបល់ជាលក្ខណៈប្រព័ន្ធជាមួយកុមារស្តីពីច្បាប់ និងគោលនយោបាយថ្មីៗ ព្រមទាំងផែនការសកម្មភាពដោយសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយ។

**ការប្រឈមទី ៨ :** ច្បាប់ពាក់ព័ន្ធនឹងសិទ្ធិកុមារ ផែនការសកម្មភាពជាតិ និងគោលនយោបាយទាំងថ្មីទាំងចាស់ តម្រូវឱ្យមានការធ្វើសមាហរណកម្មចូលទៅក្នុងវិស័យការងាររបស់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍដែលធ្វើការពាក់ព័ន្ធជាមួយកុមារ

- បង្កើតគោលការណ៍ណែនាំសម្រាប់ការបញ្ជ្រាបច្បាប់ថ្មី និងផែនការសកម្មភាពជាតិ និងគោលនយោបាយទាំងឡាយដែលសំដៅទៅរកមន្ត្រីអនុវត្ត។
- រៀបចំការបណ្តុះបណ្តាលអំពីច្បាប់សិទ្ធិកុមារ ផែនការសកម្មភាពជាតិ និងការអនុវត្តគោលនយោបាយនៅគ្រប់កម្រិតពាក់ព័ន្ធទាំងអស់ជូនដល់មន្ត្រីរដ្ឋាភិបាល កុមារ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ។

- ធ្វើសមាហរណកម្មច្បាប់ថ្មី ផែនការសកម្មភាពជាតិ និងគោលនយោបាយចូលទៅក្នុងប្រព័ន្ធផ្សព្វផ្សាយ និងយុទ្ធនាការលើកកម្ពស់ការយល់ដឹងនានា។
- រៀបចំឧបករណ៍សម្រាប់ការវិភាគ និងការវាយតម្លៃដើម្បីវាស់វែងអំពីការអនុវត្តច្បាប់ ផែនការសកម្មភាពជាតិ និងគោលនយោបាយសម្រាប់វិស័យរបស់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ។

## ផ្នែកទី៣

## ដំណើរការរៀបចំផែនការយុទ្ធសាស្ត្ររបស់ ក.ជ.ក.

ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រ ត្រូវបានចំណាយរយៈពេល ២ ខែ (ខែកញ្ញា-តុលា ឆ្នាំ២០១០) ដោយបានជ្រើសរើសជំនាញការមួយរូបដើម្បីជួយរៀបចំ និងនីតិវិធីការងារមានដូចជា ៖

១- បង្កើតក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រជាមួយអគ្គលេខាធិការដ្ឋាននៃ ក.ជ.ក. និងសិក្សាស្វែងយល់ឯកសារមួយចំនួនដែលមានស្រាប់។

២- ចុះពិគ្រោះយោបល់ ប្រមូលព័ត៌មានពីក្រសួង ស្ថាប័ន និងមន្ទីរមួយចំនួនដូចជា ៖

ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងយុត្តិធម៌ ក្រសួងកិច្ចការនារី អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ (ប.ជ.រ.ព.ភ) សមាគមជាតិកាកបាទក្រហមកម្ពុជា និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ) រាជធានីភ្នំពេញ មន្ទីរ ស.អ.យ ខេត្តកំពង់ស្ពឺ មន្ទីរ ស.អ.យ ខេត្តកណ្តាល និងអង្គការមួយចំនួនដូចជា ចលនាកុមារនិងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ អង្គការយូនីសេហ្វ អង្គការសង្គ្រោះកុមារ គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ អង្គការអ៊ិកផាតកម្ពុជា ។

៣- ពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ ឧទាហរណ៍ដូចជា មន្ត្រីរដ្ឋាភិបាល តំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ

៤- វិភាគ ៖ ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងឧបសគ្គ ការកំណត់ភាពប្រឈម និងដំណោះស្រាយសំខាន់ៗ

៥- រៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រ ក.ជ.ក. លើកទី១ ជាមួយមន្ត្រីអគ្គលេខាធិការដ្ឋាននៃ ក.ជ.ក.

៦- បង្ហាញសេចក្តីព្រាងផែនការយុទ្ធសាស្ត្រ ក.ជ.ក. ដល់សមាជិក ក.ជ.ក.

៧- អនុម័តផែនការយុទ្ធសាស្ត្រ

ក្របខ័ណ្ឌ និងឧបករណ៍សំខាន់ៗដែលទាក់ទងនឹងសិទ្ធិកុមារ ត្រូវបានបង្ហាញនៅក្នុងដំណើរការនៃការធ្វើផែនការ និងនៅក្នុងការរៀបចំផែនការយុទ្ធសាស្ត្រនេះ មានដូចជា ៖

- អនុសញ្ញាស្តីពីសិទ្ធិកុមារ និងគោលការណ៍ទាំងបួន មានឧត្តមប្រយោជន៍របស់កុមារ ការរស់រានមានជីវិតនិងអភិវឌ្ឍ ការមិនរើសអើងនិងការចូលរួមរបស់កុមារ
- សសរស្តម្ភទាំងបីនៃសកម្មភាព : សកម្មភាពឆ្លើយតបដោយផ្ទាល់ នឹងការរំលោភបំពាន និងភាពខ្វះចន្លោះនៃការបំពេញសិទ្ធិ ពង្រឹងផ្នែករចនាសម្ព័ន្ធនិងយន្តការពាក់ព័ន្ធនឹងកុមារ ពង្រឹងសមត្ថភាពសង្គមស៊ីវិលឱ្យគាំទ្រសិទ្ធិកុមារ
- ទំនាក់ទំនងរវាងអ្នកមានកាតព្វកិច្ច និងម្ចាស់សិទ្ធិ : ភាពទទួលខុសត្រូវនៃអ្នកមានកាតព្វកិច្ច និងអ្នករួមចំណែករបស់ម្ចាស់សិទ្ធិ
- ការផ្លាស់ប្តូរទាំង៥សណ្ឋាន : ការផ្លាស់ប្តូរជីវិតរបស់កុមារ ការផ្លាស់ប្តូរគោលនយោបាយ និងការអនុវត្តដែលពាក់ព័ន្ធនឹងកុមារ ការផ្លាស់ប្តូរសមធម៌ និងភាពមិនរើសអើងចំពោះកុមារ ការផ្លាស់ប្តូរការចូលរួមរបស់កុមារ និងយុវវ័យ និងការផ្លាស់ប្តូរសមត្ថភាពសង្គមស៊ីវិល និងសហគមន៍គាំទ្រសិទ្ធិកុមារ ។

# ផ្នែកទី៤

# ការពិពណ៌នាអំពីផែនការសកម្មភាព

## ៤.១- ចក្ខុវិស័យ បេសកកម្ម ទិសដៅ និងគុណតម្លៃ

### ចក្ខុវិស័យ

កុមារក្នុងប្រទេសកម្ពុជាទទួលបាននូវសិទ្ធិរបស់ពួកគេ ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញាស្តីពីសិទ្ធិកុមារ រស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ និងសម្រេចបាននូវសក្តានុពលដ៏ពិតប្រាកដរបស់ពួកគេ ។

### បេសកកម្ម

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ជាយន្តការសម្របសម្រួល ពិគ្រោះយោបល់ជូនរាជរដ្ឋាភិបាលកម្ពុជា នឹងផ្តល់នូវអនុសាសន៍ទាំងឡាយ ដើម្បីលើកកម្ពស់ការរស់រានមានជីវិតរបស់កុមារ ការរីកចម្រើនធំធាត់របស់កុមារ ការការពារកុមារ និងលើកកម្ពស់សុខុមាលភាព និងការចូលរួមរបស់កុមារ ។

### ទិសដៅ

សិទ្ធិកុមារត្រូវបានអនុវត្តយ៉ាងពេញលេញនៅក្នុងប្រទេសកម្ពុជា ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ។

### គុណតម្លៃ

- ធ្វើសហប្រតិបត្តិការ
- គណនេយ្យភាព
- សមធម៌

## ៤.២- ការកំណត់ទិសដៅ : គោលដៅយុទ្ធសាស្ត្រទាំង ៤

បន្ទាប់ពីកិច្ចពិគ្រោះយោបល់គោលដៅយុទ្ធសាស្ត្រសំខាន់ៗទាំង៤ខាងក្រោម ក.ជ.ក. ត្រូវកំណត់ដូចតទៅ :

១. ការសម្របសម្រួល សមត្ថភាព និងរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក.

២. ការលើកកម្ពស់ការយល់ដឹង និងការតស៊ូមតិដើម្បីសិទ្ធិកុមារ

៣. ការរៀបចំរបាយការណ៍ ការត្រួតពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តសិទ្ធិកុមារ

៤. ច្បាប់ និងគោលនយោបាយសម្រាប់កុមារ ។

**<u>បញ្ហាពាក់ព័ន្ធវិស័យផ្សេងទៀត</u>**

បញ្ហាមួយចំនួនដែលពាក់ព័ន្ធវិស័យផ្សេងទៀត ត្រូវបានកំណត់សម្រាប់ការបញ្ជ្រាបចូលទៅក្នុងផែនការយុទ្ធសាស្ត្រ:

១. ការចូលរួមរបស់កុមារ

២. យេនឌ័រ

៣. ពិការភាព

៤. ជាតិពន្ធុ ។

## ៤.៣- គោលដៅយុទ្ធសាស្ត្រ គោលបំណង និងសកម្មភាពរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក.

**គោលដៅយុទ្ធសាស្ត្រទី ១ : ការសម្របសម្រួល សមត្ថភាព និងរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក.**

រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក. និងសមត្ថភាពសម្របសម្រួល ព្រមទាំងធនធានជារូបវ័ន្តរបស់ ក.ជ.ក.ត្រូវបានពង្រឹងដើម្បីអនុវត្តការងារឱ្យមានប្រសិទ្ធភាពជាមួយរាជរដ្ឋាភិបាលកម្ពុជានៅគ្រប់កម្រិតទាំងអស់ និង ជាមួយភាគីពាក់ព័ន្ធសំខាន់ៗផ្សេងទៀតត្រឹមឆ្នាំ២០១៣។

**គោលបំណង ១.១ :** ពង្រឹងរចនាសម្ព័ន្ធរបស់ ក.ជ.ក. និងកសាងធនធានរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក. ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រ ២០១១-២០១៣ និងដើម្បីធានាការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា។

សកម្មភាព ១.១.១ : អនុវត្តការវិភាគទៅលើតម្រូវការនានាផ្នែកបណ្តុះបណ្តាលមន្ត្រីទាំងឡាយ កំណត់ឱ្យបាននូវកម្មវិធីបណ្តុះបណ្តាលនានា កម្មវិធីត្រួតពិនិត្យនានា ជ្រើសរើសបុគ្គលិកដែល

មានជំនាញបច្ចេកទេសជាក់លាក់ (ឧ. ផ្នែកតស៊ូមតិ ផ្នែកបង្កើតគោលនយោបាយ ផ្នែកវិភាគ និងការរៀបចំរបាយការណ៍ ផ្នែកទំនាក់ទំនង ផ្នែករៃអង្គាសមូលនិធិ ផ្នែកដឹកនាំ និងគ្រប់គ្រង និងផ្នែកបកប្រែ) ។

សកម្មភាព ១.១.២ : ពង្រឹង និងពង្រីករចនាសម្ព័ន្ធ សមត្ថភាពមន្ត្រី តួនាទី ការទទួលខុសត្រូវ និងថវិកាទ្រទ្រង់។

សកម្មភាព ១.១.៣ : ធ្វើការកំណត់ការអភិវឌ្ឍផ្នែកបច្ចេកទេសដែលត្រូវការចាំបាច់ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រ ឧ.ប្រព័ន្ធមូលដ្ឋានទិន្នន័យ ការរៀបចំគេហទំព័រមជ្ឈមណ្ឌលធនធានបច្ចេកវិទ្យាព័ត៌មាន (ITRC) ។

សកម្មភាព ១.១.៤ : រៀបចំថវិកាដើម្បីដោះស្រាយតម្រូវការរយៈពេលខ្លី រយៈពេលមធ្យម រយៈពេលវែង ឱ្យស្របនឹងផែនការយុទ្ធសាស្ត្រ ឆ្នាំ២០១១-២០១៣។

សកម្មភាព ១.១.៥ : កំណត់ដៃគូអភិវឌ្ឍថ្មីៗឱ្យឧបត្ថម្ភមូលនិធិ ឬបង្កើនធនធានមនុស្ស និងធនធានជារូបវ័ន្តរបស់ ក.ជ.ក. ។ល ។

សកម្មភាព ១.១.៦ : ធ្វើការតស៊ូមតិជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ធនធាននិងថវិកាដ៏ជាក់លាក់ដើម្បីលើកកម្ពស់ការអនុវត្តសេវា ឬសិទ្ធិកុមារ តាមរយៈវិស័យនានា។

**គោលបំណង ១.២** : ពង្រឹងសមត្ថភាពរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក. ក្នុងការសម្របសម្រួលការខិតខំប្រឹងប្រែងអន្តរក្រសួងរបស់ខ្លួនជាមួយទីភ្នាក់ងាររដ្ឋាភិបាល និងជាមួយភាគីពាក់ព័ន្ធសំខាន់ផ្សេងទៀត ដើម្បីធានាឱ្យមានការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវអនុសញ្ញាស្តីពីសិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា។

សកម្មភាព១.២.១ : លើកកម្ពស់ការយល់ដឹងអំពីតួនាទីរបស់ ក.ជ.ក. តាមរយៈការផ្សព្វផ្សាយព្រះរាជក្រឹត្យ អនុក្រឹត្យ និងផែនការយុទ្ធសាស្ត្រ។

សកម្មភាព១.២.២ : បញ្ជាក់ឱ្យច្បាស់អំពីតម្រូវការឱ្យមានវត្តមានក្នុងកិច្ចប្រជុំ អំពីតួនាទី និងការទទួលខុសត្រូវរបស់សមាជិក ក.ជ.ក. និងអត្ថប្រយោជន៍នៃការធ្វើការងារសហការដើម្បីសម្រេចបាននូវសិទ្ធិកុមារ ។

សកម្មភាព១.២.៣ : តំណាងកុមារនៅក្នុងការងាររបស់ ក.ជ.ក. និងសកម្មភាពនានារបស់សមាជិក នឹងត្រូវបានកែលម្អ ឧ.រៀបចំបទដ្ឋាន និងគោលការណ៍ណែនាំ ដើម្បីបង្កើនការចូលរួមរបស់កុមារនៅក្នុងការធ្វើសេចក្តីសម្រេច និងការប្រឹក្សាយោបល់ជាមួយកុមារ ។

សកម្មភាព ១.២.៤ : ពង្រឹងសហប្រតិបត្តិការរវាង ក.ជ.ក. ជាមួយអង្គការមិនមែនរដ្ឋាភិបាលនានាដែលធ្វើការពាក់ព័ន្ធជាមួយសិទ្ធិកុមារ និងគាំទ្រការផ្សព្វផ្សាយព័ត៌មានពីរដ្ឋាភិបាលទៅអង្គការមិនមែនរដ្ឋាភិបាលនានា។

**គោលបំណង១.៣** : ពង្រឹងតួនាទីរបស់ ក.ជ.ក. ក្នុងការសម្របសម្រួល ឬចូលរួមយ៉ាងសកម្មនៅក្នុងក្រុមការងារថ្នាក់ជាតិរបស់រាជរដ្ឋាភិបាល និងនៅក្នុងគណៈកម្មាធិការនានា។

សកម្មភាព១.៣.១ : ធ្វើការវិភាគនូវរចនាសម្ព័ន្ធគណៈកម្មាធិការ ឬក្រុមការងារដែលមានស្រាប់នៅក្នុងក្រសួង ឬខេត្ត ដើម្បីកំណត់បណ្តាញទាក់ទង ឬភាពមិនត្រួតគ្នាជាមួយក្រុមការងារថ្មី ឧ.ក្រុមការងារថ្នាក់ជាតិពហុវិស័យស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ ការជួញដូរកុមារ ។ល។

សកម្មភាព១.៣.២ : ពិនិត្យផ្ទៀងផ្ទាត់កម្រិតនៃការធ្វើសេចក្តីសម្រេចចិត្តនៃរចនាសម្ព័ន្ធខាងលើ និងបណ្តាញទាក់ទងដ៏ច្បាស់លាស់ ឬការចូលរួមពាក់ព័ន្ធជាមួយលេខាធិការដ្ឋានរបស់ ក.ជ.ក.។

សកម្មភាព១.៣.៣ : ពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធអនុគណៈកម្មការរបស់ ក.ជ.ក. ដែលមានស្រាប់ ឧ.អនុគណៈកម្មការដែលមាននៅក្នុងវិស័យទាំងឡាយ និងពង្រឹងយន្តការសម្របសម្រួលរបស់ ក.ជ.ក. ជាមួយរចនាសម្ព័ន្ធទាំងនេះ ។

សកម្មភាព១.៣.៤ : ចាត់តាំងមន្ត្រីបច្ចេកទេសដែលមានជំនាញច្បាស់លាស់ នៅក្នុងលេខាធិការដ្ឋានរបស់ ក.ជ.ក. ដើម្បីសម្របសម្រួលរវាងអនុគណៈកម្មការ និងលេខាធិការដ្ឋាន។

សកម្មភាព១.៣.៥ : ពង្រឹងយន្តការសម្របសម្រួលរបស់ ក.ជ.ក. នៅថ្នាក់ខេត្ត តាមរយៈការប្រើប្រាស់រចនាសម្ព័ន្ធមូលដ្ឋានដែលមានស្រាប់ ឧ.ផ្សារភ្ជាប់ជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារថ្នាក់ឃុំ និងធានាឱ្យមានការបង្កើតបណ្តាញទំនាក់ទំនងនៅពេលអនាគតជាមួយគណៈកម្មាធិការថ្នាក់ខេត្ត និងស្រុកថ្មីៗដែលមានលក្ខណៈស្រដៀងគ្នា។

## គោលដៅយុទ្ធសាស្ត្រទី ២ : ការលើកកម្ពស់ការយល់ដឹង និងការតស៊ូមតិដើម្បីសិទ្ធិកុមារ

សិទ្ធិរបស់កុមារដូចដែលបានចែងនៅក្នុងគណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ត្រូវបានយល់ដឹងយ៉ាងពេញលេញ និងត្រូវបានផ្តល់អាទិភាពយ៉ាងខ្ពស់ក្នុងចំណោមទីភ្នាក់ងាររដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សមាជិកសហគមន៍ មាតាបិតា និងអ្នកមានភារកិច្ចដទៃទៀត ព្រមទាំងកុមារខ្លួនឯងមានការយល់ដឹងយ៉ាងពេញលេញនូវសិទ្ធិរបស់ខ្លួន។

**គោលបំណង ២.១** : លើកកម្ពស់ការយល់ដឹង និងកំណត់អាទិភាពនូវសិទ្ធិកុមារតាមរយៈកម្មវិធីបណ្តុះបណ្តាល ព្រឹត្តិការណ៍ទាំងឡាយ និងទំនាក់ទំនងផ្សេងៗជាមួយមន្ត្រីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សមាជិក សហគមន៍ មាតាបិតា និងអ្នកមានភារកិច្ចផ្សេងទៀតនៅគ្រប់កម្រិតទាំងអស់។

សកម្មភាព ២.១.១ : ធ្វើការតស៊ូមតិជាមួយរាជរដ្ឋាភិបាល ដើម្បីចាត់ទុកជាអាទិភាពនូវបញ្ហាសិទ្ធិកុមារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការធ្វើផែនការ និងយុទ្ធសាស្ត្ររបស់ខ្លួន។

សកម្មភាព ២.១.២ : សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងព័ត៌មាន ក្រសួងទេសចរណ៍

ក្រសួង ស្ថាប័ន និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ ដើម្បីធ្វើការបញ្ជ្រាបសិទ្ធិកុមារបន្ថែមទៀតទៅក្នុងសកម្មភាពសាលារៀន សកម្មភាពបណ្តុះបណ្តាល សហគមន៍ទេសចរណ៍ វត្តអារាម ទីកន្លែងសាសនា និងអត្ថបទសារព័ត៌មានជាទៀងទាត់ ។

សកម្មភាព ២.១.៣: រៀបចំគេហទំព័រ ក.ជ.ក. និងមជ្ឈមណ្ឌលធនធានបច្ចេកវិទ្យាព័ត៌មាន (ITRC) ដើម្បីលើកកម្ពស់ការយល់ដឹងអំពីតួនាទីរបស់ ក.ជ.ក. ដែលជាទីកន្លែងធនធាន និងឯកសារយោងអំពីព័ត៌មានទាំងឡាយណាដែលទាក់ទងនឹងសិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា ។

សកម្មភាព ២.១.៤: លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកុមារជាមួយរដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ តាមរយៈការផ្សព្វផ្សាយព័ត៌មាននៅថ្នាក់ខេត្ត ស្រុក និងឃុំដោយសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលនានា ។

**គោលបំណង ២.២ :** លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកុមារដល់កុមារ និងធ្វើឱ្យពួកគេមានអំណាច ដើម្បីទាមទារសិទ្ធិរបស់ពួកគេ តាមរយៈកម្មវិធីបណ្តុះបណ្តាល និងតាមច្រកប្រាស្រ័យទាក់ទងផ្សេងទៀត ដែលពួកគេបានចូលរួមវិភាគទាន ។

សកម្មភាព ២.២.១: ធ្វើការតស៊ូមតិជាមួយក្រសួងពាក់ព័ន្ធ និងមន្ត្រីខេត្ត ដើម្បីរៀបចំគោលការណ៍ណែនាំដែលផ្តល់ការគាំទ្រ និងឱកាសសម្រាប់កុមារលើកឡើងអំពីបញ្ហាសិទ្ធិរបស់ខ្លួន ។

សកម្មភាព ២.២.២: លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកុមារជាមួយមាតាបិតា អ្នកអាណាព្យាបាល និងកុមារតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលនៅក្នុងអង្គការមិនមែនរដ្ឋាភិបាល និងធ្វើការផ្សព្វផ្សាយព័ត៌មាននៅថ្នាក់សហគមន៍ និងគ្រួសារ ដោយសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលនានា ។

សកម្មភាព ២.២.៣: បង្កើតឱកាសសម្រាប់កុមារចូលរួមនៅក្នុងក្លឹប ឬក្រុមរបស់ពួកគេ ឬចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនៅឯលំនៅឋាន សហគមន៍ និងសាលារៀន និងថ្នាក់ជាតិ ។

សកម្មភាព ២.២.៤: ធ្វើយុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយជាតិ ឧ.ទូរទស្សន៍ វិទ្យុសម្រាប់ការផ្សព្វផ្សាយទ្រង់ទ្រាយធំទូលាយនៅពេលវេលាដែលសមស្របចំពោះកុមារ និងគ្រួសារ ។

សកម្មភាព ២.២.៥: ផលិត និងចែកចាយឯកសារព័ត៌មាន ឧ.ព្រឹត្តិបត្រព័ត៌មាន ខិត្តប័ណ្ណ ផ្ទាំងរូបភាព ។

សកម្មភាព ២.២.៦: លើកកម្ពស់ការយល់ដឹងថ្នាក់ជាតិ និងព្រឹត្តិការណ៍ ដើម្បីតស៊ូមតិនានា ឧ.ទិវាកុមារអន្តរជាតិ ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ខួបផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ ។ល ។

សកម្មភាព ២.២.៧: ធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីកសាងសមត្ថភាព និងជំនាញសម្រាប់

កុមារ ដើម្បីឱ្យពួកគេអាចចូលរួមបានយ៉ាងពេញលេញនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត ។

សកម្មភាព ២.២.៨ : ផ្សព្វផ្សាយរបាយការណ៍សង្កេតសរុបមកពីគណៈកម្មការអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារដល់សមាជិក សមាជិកា ក.ជ.ក. អង្គការសង្គមស៊ីវិល និងកុមារ ព្រមទាំងជំរុញឱ្យរាជរដ្ឋាភិបាលប្រើប្រាស់អនុសាសន៍នៅក្នុងរបាយការណ៍នោះក្នុងការបង្កើតផែនការពាក់ព័ន្ធនានា ។

**គោលដៅយុទ្ធសាស្ត្រទី ៣ : ការរៀបចំរបាយការណ៍ ការពិនិត្យតាមដាន និងការវាយតម្លៃលើការអនុវត្តសិទ្ធិកុមារ**

ក.ជ.ក. មានជំនាញ និងយន្តការ ឬប្រព័ន្ធគ្រប់គ្រាន់ ដើម្បីរៀបចំរបាយការណ៍ ពិនិត្យតាមដាន និងវាយតម្លៃអំពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា ត្រឹមឆ្នាំ២០១៣ ។

**គោលបំណង ៣.១ :** កសាងជំនាញបច្ចេកទេសរបស់មន្ត្រីអគ្គលេខាធិការដ្ឋាន ក.ជ.ក ដើម្បីធានាក្នុងការធ្វើរបាយកាណ៍ ការពិនិត្យតាមដាន និងការវាយតម្លៃប្រកបដោយប្រសិទ្ធភាព ដើម្បីដាក់ជូនគណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ រាជរដ្ឋាភិបាលកម្ពុជា និងរបាយការណ៍ផ្សេងទៀតដែលចាំបាច់ទាក់ទងនឹងព័ត៌មានស្តីពីសិទ្ធិកុមារ ។

សកម្មភាព ៣.១.១ : កសាងសមត្ថភាពជំនាញបច្ចេកទេសក្នុងចំណោមមន្ត្រីអគ្គលេខាធិការដ្ឋានក.ជ.ក. សម្រាប់រៀបចំរបាយការណ៍ ដែលបំពេញតាមតម្រូវការរបស់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិ ។

សកម្មភាព ៣.១.២ : បង្កើតបណ្តាញទំនាក់ទំនងជាមួយប្រភពទិន្នន័យរបស់រាជរដ្ឋាភិបាល ឧ. CamInfo, EYMS ទិន្នន័យក្រសួងសុខាភិបាល ។

សកម្មភាព ៣.១.៣ : ធ្វើការវិភាគភាពខ្វះចន្លោះនៅក្នុងព័ត៌មានដែលអាចរកបាន សម្រាប់ធ្វើការពិនិត្យតាមដានសិទ្ធិកុមារ និងធ្វើការស្នើសុំរបាយការណ៍ថ្មីៗទៅតាមតម្រូវការចាំបាច់ ។

សកម្មភាព ៣.១.៤ : កសាងសមត្ថភាពឱ្យត្រូវតាមតម្រូវការនៃការរៀបចំរបាយការណ៍ឱ្យដល់សមាជិក ក.ជ.ក. នៅថ្នាក់ជាតិនិងខេត្ត ។ បង្កើតគោលការណ៍ណែនាំអំពីការរៀបចំរបាយការណ៍ជាភាសាខ្មែរ និងបញ្ចូលគោលការណ៍ណែនាំទាំងនេះទៅក្នុងដំណើរការ ។

សកម្មភាព ៣.១.៥ : ធានាថាភាគីពាក់ព័ន្ធ អាចស្នើសុំបានពីរដ្ឋាភិបាលនូវព័ត៌មានទាំងឡាយណាដែលទាក់ទងនឹងសិទ្ធិកុមារ ។

**គោលបំណង ៣.២ :** បង្កើតប្រព័ន្ធ និងនីតិវិធីប្រកបដោយប្រសិទ្ធភាពសម្រាប់ការពិនិត្យតាមដាន និងការវាយតម្លៃការអនុវត្តសិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា ដែលមានលក្ខណៈសុខដុមជាមួយការធ្វើផែនការ និងការរៀបចំរបាយការណ៍របស់រាជរដ្ឋាភិបាល។

សកម្មភាព ៣.២.១ : បង្កើតបណ្តាញប្រមូលទិន្នន័យផ្សារភ្ជាប់ជាមួយបណ្តាញរាយការណ៍នៅថ្នាក់ខេត្ត នាពេលបច្ចុប្បន្ន និងប្រភពទិន្នន័យនៅថ្នាក់ក្រោមជាតិ។

សកម្មភាព ៣.២.២ : បង្កើតប្រព័ន្ធមូលដ្ឋានទិន្នន័យ ក.ជ.ក. ស្តីពីបញ្ហាសិទ្ធិកុមារ និងធ្វើការបណ្តុះបណ្តាលមន្ត្រី និងសមាជិកទាំងឡាយអំពីប្រតិបត្តិការ ឬនីតិវិធី។

សកម្មភាព ៣.២.៣ : កំណត់សូចនាករ ឬទម្រង់របាយការណ៍ និងនីតិវិធីក្នុងការរាយការណ៍ជាមួយស្ថាប័នដែលរៀបចំរបាយការណ៍នោះ។

សកម្មភាព ៣.២.៤ : កសាងសមត្ថភាពដល់មន្ត្រីសំខាន់ៗក្នុងការប្រមូល នឹងវិភាគទិន្នន័យទាំងផ្នែកគុណភាព និងបរិមាណដើម្បីឱ្យមានជារបាយការណ៍ដែលមានលក្ខណៈសកម្មទុកជាមុន និងប្រកបដោយការពិចារណាល្អិតល្អន់។

សកម្មភាព ៣.២.៥ : ធ្វើការជាមួយក្រសួងផែនការដើម្បីបញ្ជ្រាបការរៀបចំរបាយការណ៍ និងការអនុវត្តស្តីពីសិទ្ធិកុមារចូលទៅក្នុងផែនការជាតិ (ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ) ផែនការតាមវិស័យ និងការធ្វើផែនការថ្នាក់ក្រោមជាតិ។

សកម្មភាព ៣.២.៦ : ប្រើប្រាស់ក្រុមការងារ ក.ជ.ក. អនុគណៈកម្មការ និង ក.ជ.ក. ថ្នាក់ខេត្តដើម្បីរៀបចំរបាយការណ៍អំពីលំហូរទិន្នន័យពីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងធ្វើការកែលម្អទៅតាមការចាំបាច់។

សកម្មភាព ៣.២.៧ : ធ្វើការអភិវឌ្ឍបទដ្ឋានជាក់ស្តែងសម្រាប់ក្រសួងពាក់ព័ន្ធស្តីពីរបៀបប្រមូលព័ត៌មាន និងការពិគ្រោះយោបល់ជាមួយកុមារ ដើម្បីធានាឱ្យមានការចូលរួមរបស់កុមារដែលប្រកបដោយអត្ថន័យ។

## គោលដៅយុទ្ធសាស្ត្រទី ៤ : ច្បាប់ និងគោលនយោបាយសម្រាប់កុមារ

ច្បាប់ និងគោលនយោបាយស្តីពីការការពារកុមារ នឹងបំពេញតាមតម្រូវការរបស់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ និងតម្រូវការជាអន្តរជាតិផ្សេងទៀត ហើយរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័នមានភារកិច្ចដទៃទៀតនឹងធ្វើសមាហរណកម្មនូវការអនុវត្តកិច្ចការទាំងនេះចូលទៅក្នុងផែនការ និងសកម្មភាពរបស់ខ្លួន។

**គោលបំណង ៤.១ :** វិភាគអំពីច្បាប់ និងគោលនយោបាយបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា កំណត់ភាពខ្វះចន្លោះ ធ្វើការតស៊ូមតិឱ្យមានការគាំទ្រចំពោះច្បាប់ និងគោលនយោបាយថ្មី ដើម្បីបំពេញឱ្យភាពខ្វះចន្លោះទាំងនេះ និងជួយដល់ការអភិវឌ្ឍនូវភាពខ្វះចន្លោះទាំងនេះ។

សកម្មភាព ៤.១.១ : ធ្វើការពិនិត្យឡើងវិញនូវច្បាប់ជាតិ អន្តរជាតិ និងគោលការណ៍ពាក់ព័ន្ធនឹងសិទ្ធិកុមារបច្ចុប្បន្ន (ឧ.ច្បាប់ពាក់ព័ន្ធនឹងកិច្ចការពារកុមារ ច្បាប់ប្រឆាំងអំពើហិង្សាលើកុមារ ច្បាប់ពាក់ព័ន្ធនឹងកេរមរតក ការបង្កើតតុលាការកុមារ ផែនការសកម្មភាពជាតិសម្រាប់កុមារ ច្បាប់ការងារពាក់ព័ន្ធនឹងកុមារ គោលនយោបាយ និងគោលនយោបាយជាតិតែមួយសម្រាប់កុមារ) ។

សកម្មភាព ៤.១.២ : ធ្វើការតស៊ូមតិជាមួយរដ្ឋាភិបាលចំពោះច្បាប់ និងគោលនយោបាយថ្មីៗ ដូចដែលកំណត់ខាងលើ ។

សកម្មភាព ៤.១.៣ : ធ្វើសេចក្តីព្រាងច្បាប់ និងគោលនយោបាយស្តីពីសិទ្ធិកុមារ និងផែនការសកម្មភាពជាតិ ឧ.ផែនការសកម្មភាពជាតិសម្រាប់កុមារ ច្បាប់ពាក់ព័ន្ធនឹងកេរមរតក ការបង្កើតតុលាការអនីតិជន គោលនយោបាយជាតិស្តីពីកុមារ ។

សកម្មភាព ៤.១.៤ : ធ្វើការពិគ្រោះយោបល់ដើម្បីធានាថា ច្បាប់ និងគោលនយោបាយទាំងឡាយមានបញ្ចូលពាក់ព័ន្ធនឹងយេនឌ័រ ពិការភាព និងជាតិពន្ធុ ។

សកម្មភាព ៤.១.៥ : ធ្វើការប្រឹក្សាយោបល់ជាលក្ខណៈប្រព័ន្ធជាមួយកុមារ និងអង្គការមិនមែនរដ្ឋាភិបាលស្តីពីច្បាប់ និងគោលនយោបាយថ្មីៗ និងផែនការសកម្មភាពនានា ។

**គោលបំណង ៤.២ :** ធានាថាច្បាប់ និងគោលនយោបាយថ្មីៗ ត្រូវបានធ្វើសមាហរណកម្មចូលទៅក្នុងផែនការតាមវិស័យរបស់រាជរដ្ឋាភិបាល និងផែនការរបស់អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងកម្មវិធីលើកកម្ពស់ការយល់ដឹងនៅគ្រប់លំដាប់ថ្នាក់ទាំងអស់ ។

សកម្មភាព ៤.២.១ : រៀបចំបង្កើតគោលការណ៍ណែនាំសម្រាប់ការបញ្ជ្រាបច្បាប់ថ្មីៗ និងផែនការសកម្មភាពជាតិ និងគោលនយោបាយសំដៅចំពោះមន្ត្រីអនុវត្ត ។

សកម្មភាព ៤.២.២ : ធ្វើការបណ្តុះបណ្តាលគ្រូបង្គោលស្តីពីច្បាប់ពាក់ព័ន្ធនឹងសិទ្ធិកុមារ ផែនការសកម្មភាពជាតិ និងការអនុវត្តគោលនយោបាយនៅថ្នាក់ដែលពាក់ព័ន្ធ ឧ.មន្ត្រីរាជរដ្ឋាភិបាល កុមារ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍនានា ។

សកម្មភាព ៤.២.៣ : ធ្វើសមាហរណកម្មច្បាប់ថ្មីៗ ផែនការសកម្មភាពជាតិ និងគោលនយោបាយទាំងឡាយចូលទៅក្នុងប្រព័ន្ធផ្សព្វផ្សាយនិងយុទ្ធនាការលើកកម្ពស់ការយល់ដឹង ។

សកម្មភាព ៤.២.៤ : បង្កើតឧបករណ៍សម្រាប់វិភាគ វាយតម្លៃឱ្យដល់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍទាំងឡាយ ដើម្បីឱ្យពួកគេប្រាកដថា ពួកគេបានអនុវត្តទៅតាមច្បាប់ ផែនការសកម្មភាពជាតិ និងគោលនយោបាយថ្មីៗ ។

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១

## អង្គការលេខ
## របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ



## អង្គការលេខ
## របស់អគ្គលេខាធិការដ្ឋាន ក.ជ.ក.



# សេចក្តីសង្ខេបការវិភាគ SWOT

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| ➢ តួនាទីរបស់ ក.ជ.ក. គឺជាតួនាទីមួយដ៏មានសារៈសំខាន់ ។<br>➢ ព្រះរាជក្រឹត្យ និងអនុក្រឹត្យថ្មីនឹងផ្តល់ឱ្យមានការជឿទុកចិត្តទៅលើ ក.ជ.ក. និងផ្តល់នូវវចនាសម្ព័ន្ធកាន់តែទូលំទូលាយនៅថ្នាក់ក្រោមជាតិ ។<br>➢ សម្តេចនាយករដ្ឋមន្ត្រីដែលជាប្រធានកិត្តិយស ។<br>➢ អគ្គលេខាធិការ ក.ជ.ក. មានបទពិសោធន៍ និងមានទំនាក់ទំនងល្អៗ ។<br>➢ ផែនការយុទ្ធសាស្ត្រលើកទី១ របស់ ក.ជ.ក. គឺជាភាពខ្លាំងមួយ ។<br>➢ មានគំនិតផ្តួចផ្តើមធ្វើការវិភាគច្បាប់ និងបទបញ្ញាទាក់ទងនឹងការការពារកុមារ ។<br>➢ ធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងយុត្តិធម៌ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។<br>➢ ស្វាគមន៍ការផ្តួចផ្តើមគំនិតថ្មីៗនៅថ្នាក់ខេត្ត ។<br>➢ រៀបចំទិវាទិវាកុមារអន្តរជាតិ និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ។<br>➢ ផែនការសកម្មភាពប្រចាំឆ្នាំរបស់ ក.ជ.ក. ។ | ➢ តួនាទីរបស់ ក.ជ.ក. មិនទាន់មានការយល់ដឹងបានទូលំទូលាយ ។<br>➢ ពុំទាន់មានការបែងចែកថវិកាសម្រាប់ ក.ជ.ក. ។<br>➢ ផែនការពាក់ព័ន្ធនឹងសិទ្ធិកុមារមានលក្ខណៈរប៉ាត់រប៉ាយ ឧ.ក្រុមការងារថ្នាក់ជាតិពហុវិស័យស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ ការជួញដូរ យុត្តិធម៌អនីតិជន និងគ្មានគោលនយោបាយជាតិមួយសម្រាប់កុមារ ។<br>➢ អនុគណៈកម្មការរបស់ ក.ជ.ក. ខ្វះ មិនមានតំណាងមន្ត្រីអគ្គលេខាធិការដ្ឋានចូលរួម ដែលធ្វើឱ្យមានការពិបាកក្នុងការតាមដានការអនុវត្តសិទ្ធិកុមារ ។<br>➢ តម្រូវការឱ្យមានតួនាទីច្បាស់លាស់ជាមួយភ្នាក់ងារអនុវត្តដើម្បីជំរុញការអនុវត្តសិទ្ធិកុមារ ។<br>➢ ការពិនិត្យតាមដានរបស់ ក.ជ.ក. តម្រូវការចាំបាច់នូវសូចនាករច្បាស់លាស់ទម្រង់នៃការរៀបចំរបាយការណ៍ នីតិវិធី និងទិន្នន័យមូលដ្ឋាន ។<br>➢ ពុំទាន់មានការពិនិត្យតាមដានគ្រប់គ្រាន់លើការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិកុមារ ។<br>➢ ស្ថិតិរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងបញ្ហាកុមារ នៅពុំទាន់មានគ្រប់គ្រាន់នៅឡើយ ។<br>➢ កង្វះធនធានហិរញ្ញវត្ថុ និងធនធានមនុស្សសម្រាប់ធ្វើការវិភាគទិន្នន័យ ។ ចាំបាច់ត្រូវមានការព្យាករណ៍ថវិកាទុកជាមុន ។<br>➢ ការរៀបចំរបាយការណ៍ផ្ញើជូនគណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារនៃអង្គការសហប្រជាជាតិមានសកម្មភាពកាន់តែកើនឡើង ។<br>➢ កង្វះធនធានរូបវន្ត និងហិរញ្ញវត្ថុ ។<br>➢ កង្វះជំនាញបច្ចេកទេស ។ |

| ឱកាស | ឧបសគ្គ |
|---|---|
| ➢ ធ្វើការវិភាគច្បាប់ជាតិ និងអន្តរជាតិដើម្បីកំណត់ពីយុទ្ធសាស្ត្រភាពខ្វះចន្លោះនាពេលអនាគតសម្រាប់ច្បាប់ និងគោលនយោបាយ។<br>➢ ធ្វើការជាមួយក្រសួងផែនការដើម្បីកសាងសមត្ថភាពផ្នែកប្រមូលទិន្នន័យ ការពិនិត្យតាមដាន និងភាពសមស្របជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ។<br>➢ វិភាគភាពខ្វះចន្លោះនៅក្នុងព័ត៌មានដែលអាចរកបានសម្រាប់ធ្វើការពិនិត្យតាមដានអនុសញ្ញាស្តីពីសិទ្ធិកុមារ និងសំណើសុំឱ្យរៀបចំរបាយការណ៍ថ្មី១។<br>➢ ក្រុមការងារកុមារនៅតាមក្រសួង ស្ថាប័នដែលទើបបានបង្កើតនឹងធ្វើឱ្យ ក.ជ.ក. មាន ភាពងាយស្រួលក្នុងការធ្វើទំនាក់ទំនង។<br>➢ ការកែសម្រួលរចនាសម្ព័ន្ធអនុគណៈកម្មការនឹងលើកកម្ពស់ប្រសិទ្ធភាពរបស់ ក.ជ.ក.។<br>➢ ក្រុមការងារកុមារនៅតាមក្រសួង ស្ថាប័ននឹងជំរុញការអនុវត្តសិទ្ធិកុមារតាមវិស័យ។<br>➢ រចនាសម្ព័ន្ធថ្នាក់ខេត្ត មានភាពងាយស្រួលក្នុងការប្រមូលរបាយការណ៍។<br>➢ សហការជាមួយអង្គការមិនមែនរដ្ឋាភិបាលបណ្តុះបណ្តាលជនបង្គោលជាទៀងទាត់<br>➢ ក.ជ.ក. អាចធ្វើការតស៊ូមតិជាមួយរាជរដ្ឋាភិបាល។<br>➢ ក.ជ.ក. អាចជួយកុមារឱ្យទាមទារបាននូវសិទ្ធិរបស់ពួកគេ។<br>➢ ផ្តល់ឱកាសដល់កុមារបានចូលរួម។<br>➢ មានឱកាសទទួលមូលនិធិ និងបច្ចេកទេសពីដៃគូអភិវឌ្ឍ។<br>➢ ការពិគ្រោះយោបល់បន្ថែមទៀតជាមួយភាគីពាក់ព័ន្ធរបស់ ក.ជ.ក. អំពីការធ្វើផែនការយុទ្ធសាស្ត្រនាពេលអនាគត។<br>➢ លើកកម្ពស់ការយល់ដឹងដល់អ្នកមានភារកិច្ច និងកុមារ។<br>➢ ធានាថាកុមារគ្រប់រូបមានតំណាងនៅក្នុងការងាររបស់ ក.ជ.ក. ឧ.កុមារជនជាតិ កុមារពិការ យេនឌ័រ។ | ➢ តំណាង ក.ជ.ក. ថ្នាក់ខេត្តត្រូវការនូវយន្តការ តួនាទីដ៏ជាក់លាក់ ប្រសិនបើមិនមានភាពជាក់លាក់អ្នកទទួលខុសត្រូវថ្មីអាចកំណត់ចេញនូវអាទិភាពផ្សេងទៀត។<br>➢ តួនាទីរបស់ ក.ជ.ក. ពេលខ្លះមានការភ័ន្តច្រឡំទៅជាអ្នកអនុវត្ត ហើយវាជាន់គ្នានឹងការងារខ្លះរបស់ក្រសួងនៅថ្នាក់ខេត្ត។<br>➢ ក្រុមការងារថ្មីនៅថ្នាក់ក្រសួងអាចមើលឃើញថាគ្រាន់តែជាការជួបប្រជុំគ្នាមួយទៀតប៉ុណ្ណោះ និងមិនមែនជាបណ្តាញផ្សារភ្ជាប់ដ៏ល្អទៅនឹងគណៈកម្មាធិការ និងក្រុមការងារដែលមានស្រាប់នោះទេ។ ក.ជ.ក. ត្រូវធ្វើការវិភាគអំពីភាពស៊ីចង្វាក់គ្នាជាមួយនឹងរចនាសម្ព័ន្ធ ដែលមានស្រាប់។ |

# ផែនការសកម្មភាព

**ផែនការយុទ្ធសាស្ត្ររយៈពេល ៣ ឆ្នាំ ២០១១-២០១៣ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

**គោលដៅយុទ្ធសាស្ត្រទី ១ : ការសម្របសម្រួល សមត្ថភាព និងរចនាសម្ព័ន្ធ របស់អគ្គលេខាធិការដ្ឋាន ក.ជ.ក.**

**គោលដៅយុទ្ធសាស្ត្រទី ១ :**

រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក. និងសមត្ថភាពសម្របសម្រួល ព្រមទាំងធនធានជារូបវ័ន្តរបស់ ក.ជ.ក. ត្រូវបានពង្រឹងដើម្បីអនុវត្តការងារឱ្យមានប្រសិទ្ធភាពជាមួយរាជរដ្ឋាភិបាលកម្ពុជានៅគ្រប់កម្រិតទាំងអស់ និងជាមួយភាគីពាក់ព័ន្ធសំខាន់ៗផ្សេងៗទៀត ត្រឹមឆ្នាំ២០១៣ ។

| គោលបំណងយុទ្ធសាស្ត្រ | សកម្មភាព | សូចនាករអំពីការបំពេញភារកិច្ច | រយៈពេល | | |
|---|---|---|---|---|---|
| | | | ២០១១ | ២០១២ | ២០១៣ |
| **គោលបំណង ១.១ :** ពង្រឹងរចនាសម្ព័ន្ធរបស់ ក.ជ.ក. និងកសាងធនធានរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក. ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រ ២០១១-២០១៣ និងដើម្បី | ១.១.១- អនុវត្តការវិភាគទៅលើតម្រូវការនានា ផ្នែកបណ្តុះបណ្តាលមន្ត្រីទាំងឡាយ កំណត់ឱ្យបាននូវកម្មវិធីបណ្តុះបណ្តាលនានា កម្មវិធីពិនិត្យតាមដាននានា ការជ្រើសរើសមន្ត្រីដែលមានជំនាញបច្ចេកទេសជាក់លាក់ ( ឧ.ការតស៊ូមតិ ការបង្កើតគោលនយោបាយ ផ្នែកវិភាគ និងរៀបចំរបាយការណ៍ ផ្នែក | ចំនួនមន្ត្រីអគ្គលេខាធិការដ្ឋាន ក.ជ.ក. កើនឡើង និងបង្ហាញនូវចំណេះដឹង និងជំនាញថ្មី | x | | |

| | | | | | |
|---|---|---|---|---|---|
| ធានាការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ នៅក្នុងប្រទេសកម្ពុជា។ | ទំនាក់ទំនង ផ្នែកវែអង្គាសមូលនិធិ ផ្នែកដឹកនាំ និងគ្រប់គ្រង ផ្នែក បកប្រែ) ។ | | | | |
| | ១.១.២- ពង្រឹង និងពង្រីករចនាសម្ព័ន្ធ សមត្ថភាពមន្ត្រី តួនាទី ការទទួលខុសត្រូវ និងថវិកាទ្រទ្រង់ ។ | ការបែងចែកថវិកាពីរាជរដ្ឋាភិបាលនឹងកើនឡើងជាប្រចាំឆ្នាំ ដើម្បីសម្រេចឱ្យបាននូវផែនការយុទ្ធសាស្ត្រ | x | | |
| | ១.១.៣- ធ្វើការកំណត់ការអភិវឌ្ឍផ្នែកបច្ចេកទេសដែលត្រូវការចាំបាច់ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រ ឧ.ប្រព័ន្ធមូលដ្ឋានទិន្នន័យ ការរៀបចំគេហទំព័រមជ្ឈមណ្ឌលធនធានបច្ចេកវិទ្យាព័ត៌មាន ( ITRC) ។ | ចំនួនទីភ្នាក់ងារផ្តល់ជំនួយថ្មីៗ បានទ្រទ្រង់ហិរញ្ញវត្ថុដល់គម្រោង ក.ជ.ក. | x | | |
| | ១.១.៤- រៀបចំថវិកាដើម្បីដោះស្រាយតម្រូវការរយៈពេលខ្លី រយៈពេលមធ្យម រយៈពេលវែងឱ្យស្របនឹងផែនការយុទ្ធសាស្ត្រ ២០១១-២០១៣។ | | x | | |
| | ១.១.៥- កំណត់ដៃគូអភិវឌ្ឍថ្មីៗឱ្យឧបត្ថម្ភមូលនិធិ ឬបង្កើនធនធានមនុស្ស និងធនធានជារូបវន្តរបស់ ក.ជ.ក..។ល ។ | | x | x | x |
| | ១.១.៦- ធ្វើការតស៊ូមតិជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់ធនធាន និងថវិកាដ៏ជាក់លាក់ដើម្បីលើកកម្ពស់ការអនុវត្តសេវា ឬសិទ្ធិកុមារ តាមរយៈវិស័យនានា។ | | x | x | x |

| | | | | | |
|---|---|---|---|---|---|
| **គោលបំណង ១.២ :** ពង្រឹងសមត្ថភាពរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក. ក្នុងការសម្របសម្រួល ការខិតខំប្រឹងប្រែងអន្តរក្រសួងរបស់ខ្លួនជាមួយទីភ្នាក់ងាររដ្ឋាភិបាល និងជាមួយភាគីពាក់ព័ន្ធសំខាន់ៗផ្សេងទៀត ដើម្បីធានាឱ្យមានការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវអនុសញ្ញា ស្តីពីសិទ្ធិកុមារ នៅក្នុងប្រទេសកម្ពុជា។ | ១.២.១- លើកកម្ពស់ការយល់ដឹងអំពីតួនាទីរបស់ ក.ជ.ក. តាមរយៈការផ្សព្វផ្សាយព្រះរាជក្រឹត្យ អនុក្រឹត្យ និងផែនការយុទ្ធសាស្ត្រ។ | យ៉ាងហោចណាស់មានជនបង្គោលរបស់រដ្ឋាភិបាលប្រហែល ៦០% របស់ ក.ជ.ក. ចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាព និងផែនការរបស់ ក.ជ.ក.។ | x | | |
| | ១.២.២- បញ្ជាក់ឱ្យបានច្បាស់អំពីតម្រូវការឱ្យមានវត្តមានក្នុងកិច្ចប្រជុំ អំពីតួនាទី និងការទទួលខុសត្រូវរបស់សមាជិក ក.ជ.ក. និងអត្ថប្រយោជន៍នៃការធ្វើការងារសហការ ដើម្បីសម្រេចបាននូវសិទ្ធិកុមារ។ | ផែនការ និងឯកសារមួយចំនួនពីក្រសួងពាក់ព័ន្ធនឹងបញ្ចូលសិទ្ធិកុមារទៅក្នុងការងាររបស់ខ្លួន និងទៅក្នុងតួនាទីរបស់មន្ត្រីកាន់តែច្រើន។ | x | | |
| | ១.២.៣- តំណាងកុមារនៅក្នុងការងាររបស់ ក.ជ.ក. និងសកម្មភាពនានារបស់សមាជិកនឹងត្រូវបានកែលម្អ ឧ.រៀបចំបទដ្ឋាន និងគោលការណ៍ណែនាំ ដើម្បីបង្កើនការចូលរួមរបស់កុមារ នៅក្នុងការធ្វើសេចក្តីសម្រេច និងការប្រឹក្សាយោបល់ជាមួយកុមារ។ | នីតិវិធីត្រូវបានព្រមព្រៀង ហើយកិច្ចពិគ្រោះយោបល់មួយចំនួនត្រូវបានរៀបចំឡើងជាមួយកុមារ។ | x | x | |
| | ១.២.៤- ពង្រឹងសហប្រតិបត្តិការរវាង ក.ជ.ក. ជាមួយអង្គការមិនមែនរដ្ឋាភិបាលនានាដែលធ្វើការពាក់ព័ន្ធជាមួយសិទ្ធិកុមារ និងគាំទ្រការផ្សព្វផ្សាយព័ត៌មានពីរដ្ឋាភិបាលទៅអង្គការមិនមែនរដ្ឋាភិបាលនានា។ | មន្ត្រីរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនប្រើប្រាស់មន្ត្រីសម្របសម្រួលជាមួយអង្គការមិនមែនរដ្ឋាភិបាល។ | x | x | x |

| | | | | | |
|---|---|---|---|---|---|
| **គោលបំណង ១.៣ :** ពង្រឹងតួនាទីរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក ក្នុងការសម្របសម្រួល ឬចូលរួមយ៉ាងសកម្មនៅក្នុងក្រុមការងារថ្នាក់ជាតិរបស់រាជរដ្ឋាភិបាល និងនៅក្នុងគណៈកម្មាធិការនានា។ | ១.៣.១- ធ្វើការវិភាគនូវរចនាសម្ព័ន្ធគណៈកម្មាធិការ ឬក្រុមការងារដែលមានស្រាប់នៅក្នុងក្រសួង ឬខេត្ត ដើម្បីកំណត់បណ្តាញទាក់ទង ឬភាពមិនត្រួតគ្នាជាមួយក្រុមការងារថ្មី ឧ.ក្រុមការងារថ្នាក់ជាតិពហុវិស័យស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ ការជួញដូរកុមារ ។ល។ | ក្រុមការងារថ្នាក់ជាតិដែលមានស្រាប់មួយចំនួន ឬគណៈកម្មាធិការទទួលស្គាល់ ក.ជ.ក. ជាចំណុចគោលនៃសិទ្ធិកុមារនៅក្នុងគណៈកម្មាធិការរបស់ខ្លួន។ | x | | |
| | ១.៣.២-ពិនិត្យផ្ទៀងផ្ទាត់កម្រិតនៃការធ្វើសេចក្តីសម្រេចចិត្តនៃរចនាសម្ព័ន្ធខាងលើ និងបណ្តាញទាក់ទងដ៏ច្បាស់លាស់ការចូលរួមពាក់ព័ន្ធជាមួយលេខាធិការដ្ឋានរបស់ ក.ជ.ក.។ | សកម្មភាពសម្របសម្រួលមួយចំនួនរវាងលេខាធិការដ្ឋានរបស់ ក.ជ.ក. និងក្រុមការងារអនុគណៈកម្មការ ឬ ក.ជ.ក. នៅថ្នាក់ខេត្ត។ | x | | |
| | ១.៣.៣- ពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធអនុគណៈកម្មការរបស់ ក.ជ.ក. ដែលមានស្រាប់ ឧ.អនុគណៈកម្មការដែលមាននៅក្នុងវិស័យទាំងឡាយ និងពង្រឹងយន្តការសម្របសម្រួលរបស់ ក.ជ.ក. ជាមួយរចនាសម្ព័ន្ធទាំងនេះ។ | | x | | |
| | ១.៣.៤- ចាត់តាំងមន្ត្រីបច្ចេកទេសដែលមានជំនាញច្បាស់លាស់នៅក្នុងលេខាធិការដ្ឋានរបស់ ក.ជ.ក. ដើម្បីសម្របសម្រួលរវាងអនុគណៈកម្មការ និងលេខាធិការដ្ឋាន។ | | x | | |
| | ១.៣.៥- ពង្រឹងយន្តការសម្របសម្រួលរបស់ ក.ជ.ក. នៅថ្នាក់ខេត្ត តាមរយៈការប្រើប្រាស់រចនាសម្ព័ន្ធមូលដ្ឋានដែល | | x | x | |

| | | | | | |
|---|---|---|---|---|---|
| | មានស្រាប់ ឧ.ផ្សារភ្ជាប់ជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារថ្នាក់ឃុំ និងធានាឱ្យមានការបង្កើតបណ្តាញទំនាក់ទំនងនៅពេលអនាគតជាមួយគណៈកម្មាធិការថ្នាក់ខេត្ត និងស្រុកថ្មីដែលមានលក្ខណៈស្រដៀងគ្នា។ | | | | |

**គោលដៅយុទ្ធសាស្ត្រទី ២ : ការលើកកម្ពស់ការយល់ដឹង និងការគាំទ្រដើម្បីសិទ្ធិកុមារ**

**គោលដៅយុទ្ធសាស្ត្រទី ២ :**

សិទ្ធិរបស់កុមារដូចដែលបានចែងនៅក្នុងគណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ត្រូវបានយល់ដឹងយ៉ាងពេញលេញ និងចាត់ទុកជាអាទិភាពខ្ពស់ក្នុងចំណោមទីភ្នាក់ងាររាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សមាជិកសហគមន៍ មាតាបិតា និងអ្នកមានភារកិច្ចដទៃទៀត ព្រមទាំងកុមារខ្លួនឯងមានការយល់ដឹងយ៉ាងពេញលេញនូវសិទ្ធិរបស់ខ្លួន។

| **គោលបំណងយុទ្ធសាស្ត្រ** | **សកម្មភាព** | **សូចនាករអំពីការបំពេញភារកិច្ច** | **រយៈពេល** | | |
|---|---|---|---|---|---|
| | | | **២០១១** | **២០១២** | **២០១៣** |
| **គោលបំណង ២.១ :** លើកកម្ពស់ការយល់ដឹង និងកំណត់អាទិភាពនូវសិទ្ធិកុមារតាមរយៈកម្មវិធីបណ្តុះបណ្តាល ព្រឹត្តិការណ៍ទាំងឡាយ និងទំនាក់ទំនងផ្សេងជាមួយមន្ត្រី | ២.១.១- ស្វែងរកការគាំទ្រពីរដ្ឋាភិបាល ដើម្បីចាត់ទុកជាអាទិភាពនូវបញ្ហាសិទ្ធិកុមារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការធ្វើផែនការ និងយុទ្ធសាស្ត្ររបស់ខ្លួន។ | មានមន្ត្រីរដ្ឋាភិបាលយ៉ាងតិច៥០% ដែលបានទទួលការបណ្តុះបណ្តាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបង្កើនអាទិភាពរបស់ខ្លួនទាក់ទងនឹងសិទ្ធិកុមារ នៅក្នុងយុទ្ធសាស្ត្រ និងការធ្វើផែនការរបស់ខ្លួន។ | x | x | x |

| | | | | | |
|---|---|---|---|---|---|
| រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សមាជិកសហគមន៍ មាតាបិតា និងអ្នកមានភារកិច្ចផ្សេងទៀតនៅគ្រប់កម្រិតទាំងអស់ ។ | ២.១.២- សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងព័ត៌មាន ក្រសួងទេសចរណ៍ ក្រសួងស្ថាប័ន និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ ដើម្បីធ្វើការបញ្ជ្រាបសិទ្ធិកុមារបន្ថែមទៀតទៅក្នុងសកម្មភាពសាលារៀន សកម្មភាពបណ្តុះបណ្តាល សហគមន៍ទេសចរណ៍ វត្តអារាម ទីកន្លែងសាសនា និងអត្ថបទសារព័ត៌មានជាទៀងទាត់ ។ | មានសាលារៀនយ៉ាងតិច ៥០%នឹងបញ្ចូលសកម្មភាព និងអត្ថបទសារព័ត៌មានថ្មីៗ ដើម្បីលើកកម្ពស់អនុសញ្ញាស្តីពីសិទ្ធិកុមារជារៀងរាល់ឆ្នាំ ។ | x | x | x |
| | ២.១.៣- រៀបចំគេហទំព័រ ក.ជ.ក. និងមជ្ឈមណ្ឌលធនធានបច្ចេកវិទ្យាព័ត៌មាន (ITRC) ដើម្បីលើកកម្ពស់ការយល់ដឹងអំពីតួនាទីរបស់ ក.ជ.ក. ដែលជាកន្លែងធនធាន និងឯកសារយោងអំពីព័ត៌មានទាំងឡាយណាដែលទាក់ទងនឹងសិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា ។ | មានចំនួនអ្នកទស្សនាគេហទំព័ររបស់ ក.ជ.ក. និង មជ្ឈមណ្ឌលធនធានបច្ចេកវិទ្យាព័ត៌មាន (ITRC ) ។ | x | x | |
| | ២.១.៤- លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកុមារជាមួយរដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ តាមរយៈការផ្សព្វផ្សាយព័ត៌មាននៅថ្នាក់ខេត្ត ស្រុក និងឃុំដោយសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលនានា ។ | មានអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនធ្វើការជាបណ្តាញដើម្បីផ្សព្វផ្សាយព័ត៌មាននៅថ្នាក់ក្រោមជាតិ ។ | x | x | x |

| | | | | | |
|---|---|---|---|---|---|
| **គោលបំណង ២.២ :** លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកុមារ ដល់កុមារ និងធ្វើឱ្យពួកគេមានអំណាច ដើម្បីទាមទារសិទ្ធិរបស់ពួកគេតាមរយៈកម្មវិធីបណ្តុះបណ្តាល និងតាមច្រកប្រាស្រ័យទាក់ទងផ្សេងទៀត ដែលពួកគេបានចូលរួមវិភាគទាន ។ | ២.២.១- ធ្វើការតស៊ូមតិជាមួយក្រសួងពាក់ព័ន្ធ និងមន្ត្រីខេត្ត ដើម្បីរៀបចំគោលការណ៍ណែនាំដែលផ្តល់ការគាំទ្រ និងឱកាសសម្រាប់កុមារលើកឡើងអំពីបញ្ហាសិទ្ធិរបស់ខ្លួន ។ | មានក្រុមគោលដៅយ៉ាងតិច ៥០%បានយល់ដឹងអំពីសិទ្ធិកុមារ និងគាំទ្រកុមារឱ្យពួកគេទទួលបាននូវសិទ្ធិរបស់ពួកគេ ។ | x | x | x |
| | ២.២.២- លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកុមារជាមួយមាតាបិតា អ្នកអាណាព្យាបាល និងកុមារ តាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលនៅក្នុងអង្គការមិនមែនរដ្ឋាភិបាល និងធ្វើការផ្សព្វផ្សាយព័ត៌មាននៅថ្នាក់សហគមន៍ និងគ្រួសារ ដោយសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលនានា ។ | ក្រសួងស្ថាប័ន និងអាជ្ញាធរ ខេត្ត ស្រុកមួយចំនួននឹងផ្តល់ឱកាសសម្រាប់កុមារ ចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅតាមលំនៅឋានសហគមន៍ និងសាលារៀន ។ | x | x | x |
| | ២.២.៣- បង្កើតឱកាសសម្រាប់កុមារចូលរួមនៅក្នុងក្លឹប ឬក្រុមរបស់ពួកគេ ឬនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនៅឯលំនៅឋានសហគមន៍ និងសាលារៀនតាមរយៈ សកម្មភាពលើកកម្ពស់ការយល់ដឹងនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ។ | សកម្មភាពមួយចំនួនត្រូវបានអនុវត្តដោយកុមារ និងគាំទ្រដោយនីតិជន ដើម្បីលើកកម្ពស់សិទ្ធិកុមារ និងស្វែងរកការគាំទ្រសិទ្ធិកុមារនៅកម្រិតផ្សេងៗគ្នា ។ | x | x | x |
| | ២.២.៤- ធ្វើយុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយជាតិ ឧ.ទូរទស្សន៍ វិទ្យុសម្រាប់ការផ្សព្វផ្សាយទ្រង់ទ្រាយធំទូលាយនៅពេលវេលាដែលសមស្របចំពោះកុមារ និងគ្រួសារ ។ | ឯកសារព័ត៌មានមួយចំនួនត្រូវបានចែកចាយ ហើយសកម្មភាពទាំងឡាយត្រូវបានធ្វើឱ្យសម្រេច ។ | x | x | x |
| | ២.២.៥- ផលិត និងចែកចាយឯកសារព័ត៌មាន ឧ.ព្រឹត្តិបត្រព័ត៌មាន ខិត្តប័ណ្ណ ផ្ទាំងរូបភាព ។ | | x | x | x |

| | | | | | |
|---|---|---|---|---|---|
| | ២.២.៦- លើកកម្ពស់ការយល់ដឹងថ្នាក់ជាតិ និងព្រឹត្តិការណ៍ដើម្បីតស៊ូមតិនានា ឧ.ទិវាកុមារអន្តរជាតិ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ខួបផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ ។ល។ | | x | x | x |
| | ២.២.៧- ធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីកសាងសមត្ថភាព និងជំនាញសម្រាប់កុមារ ដើម្បីឱ្យពួកគេអាចចូលរួមបានយ៉ាងពេញលេញនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត ។ | | x | x | x |
| | ២.២.៨- ផ្សព្វផ្សាយរបាយការណ៍សង្កេតសរុបមកពីគណៈកម្មការអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារដល់សមាជិកសមាជិកា ក.ជ.ក. អង្គការសង្គមស៊ីវិល និងកុមារ ព្រមទាំងជំរុញឱ្យរាជរដ្ឋាភិបាលប្រើប្រាស់អនុសាសន៍នៅក្នុងរបាយការណ៍នោះក្នុងការបង្កើតផែនការពាក់ព័ន្ធនានា ។ | | x | x | |

**គោលដៅយុទ្ធសាស្ត្រទី ៣ : ការរៀបចំរបាយការណ៍ ការពិនិត្យតាមដាន និងការវាយតម្លៃលើការអនុវត្តសិទ្ធិកុមារ**

**គោលដៅយុទ្ធសាស្ត្រទី ៣ :**

ក.ជ.ក. មានជំនាញ យន្តការ ឬប្រព័ន្ធគ្រប់គ្រាន់ ដើម្បីរៀបចំរបាយការណ៍ ពិនិត្យតាមដាន និងវាយតម្លៃអំពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា ត្រឹមឆ្នាំ ២០១៣។

| គោលបំណងយុទ្ធសាស្ត្រ | សកម្មភាព | សូចនាករអំពីការបំពេញភារកិច្ច | រយៈពេល ២០១១ | រយៈពេល ២០១២ | រយៈពេល ២០១៣ |
|---|---|---|---|---|---|
| **គោលបំណង ៣.១ :** កសាងជំនាញបច្ចេកទេសរបស់មន្ត្រីអគ្គលេខាធិការដ្ឋានក.ជ.ក. ដើម្បីធានាក្នុងការរៀបចំរបាយការណ៍ ការពិនិត្យតាមដាន និងការវាយតម្លៃប្រកបដោយប្រសិទ្ធភាព ដើម្បីដាក់ជូនគណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិ រាជរដ្ឋាភិបាលកម្ពុជា និងរបាយការណ៍ផ្សេងទៀត ដែលចាំបាច់ទាក់ទងនឹងព័ត៌មានស្តីពីសិទ្ធិកុមារ ។ | ៣.១.១- កសាងសមត្ថភាពជំនាញបច្ចេកទេសក្នុងចំណោមមន្ត្រីអគ្គលេខាធិការដ្ឋាន ក.ជ.ក. សម្រាប់រៀបចំរបាយការណ៍ ដែលបំពេញតាមតម្រូវការរបស់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិ ។ | មន្ត្រីរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក.បានកែលម្អជំនាញរៀបចំរបាយការណ៍បាន ៥០% ។ | x | x | |
| | ៣.១.២- បង្កើតបណ្តាញទំនាក់ទំនងជាមួយប្រភពទិន្នន័យរបស់រាជរដ្ឋាភិបាល ឧ. CamInfo, EYMS ទិន្នន័យក្រសួងសុខាភិបាល ។ | សមាជិក ក.ជ.ក. បានបង្កើនចំណេះដឹងនៅក្នុងការរៀបចំ និងការអនុវត្តការរៀបចំរបាយការណ៍អំពីអនុសញ្ញាស្តីពីសិទ្ធិកុមារ និងរបាយការណ៍អំពីពិធីសារបន្ថែម ។ | x | | |
| | ៣.១.៣- ធ្វើការវិភាគភាពខ្វះចន្លោះនៅក្នុងព័ត៌មានដែលអាចរកបាន សម្រាប់ធ្វើការពិនិត្យតាមដានសិទ្ធិកុមារ និងធ្វើការស្នើសុំរបាយការណ៍ថ្មីៗទៅតាមតម្រូវការចាំបាច់ ។ | មានការកើនឡើងនូវការទទួលបាននូវចំនួនរបាយការណ៍របស់រាជរដ្ឋាភិបាល ដោយអង្គការមិនមែនរដ្ឋាភិបាល និងកុមារទាក់ទងនឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ ។ | x | x | x |

| | | | | | |
|---|---|---|---|---|---|
| | ៣.១.៤- កសាងសមត្ថភាពឱ្យត្រូវតាមតម្រូវការនៃការធ្វើរបាយការណ៍ឱ្យដល់សមាជិក ក.ជ.ក. នៅថ្នាក់ជាតិ និងខេត្ត ។ បង្កើតគោលការណ៍ណែនាំអំពីការរៀបចំរបាយការណ៍ជាភាសាខ្មែរ និងបញ្ចូលគោលការណ៍ណែនាំទាំងនេះទៅក្នុងដំណើរការ ។ | | x | x | |
| | ៣.១.៥- ធានាថាភាគីពាក់ព័ន្ធ អាចស្នើសុំបានពីរដ្ឋាភិបាលនូវព័ត៌មានទាំងឡាយណាដែលទាក់ទងនឹងសិទ្ធិកុមារ ។ | | x | x | x |
| **គោលបំណង ៣.២ :**<br>បង្កើតប្រព័ន្ធ និងនីតិវិធីប្រកបដោយប្រសិទ្ធភាពសម្រាប់ការពិនិត្យតាមដាន និងការវាយតម្លៃការអនុវត្តសិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា ដែលមានលក្ខណៈសុខដុមជាមួយការធ្វើផែនការ និងរបាយការណ៍របស់រាជរដ្ឋាភិបាល ។ | ៣.២.១- បង្កើតបណ្តាញប្រមូលទិន្នន័យផ្សារភ្ជាប់ជាមួយបណ្តាញរាយការណ៍នៅថ្នាក់ខេត្តនាពេលបច្ចុប្បន្ន និងប្រភពទិន្នន័យនៅថ្នាក់ក្រោមជាតិ ។ | គោលការណ៍ណែនាំ នីតិវិធី និងទម្រង់សម្រាប់ធ្វើការពិនិត្យតាមដានប្រព័ន្ធត្រូវបានធ្វើការអភិវឌ្ឍ និងការបណ្តុះបណ្តាលត្រូវបានផ្តល់ឱ្យសមាជិកពាក់ព័ន្ធនៅថ្នាក់ជាតិ និងក្រោមជាតិ ។ | x | | |
| | ៣.២.២- បង្កើតប្រព័ន្ធមូលដ្ឋានទិន្នន័យ ក.ជ.ក. ស្តីពីបញ្ហាសិទ្ធិកុមារ និងធ្វើការបណ្តុះបណ្តាលមន្ត្រី និងសមាជិកទាំងឡាយអំពីប្រតិបត្តិការ ឬនីតិវិធី ។ | ផែនការជាតិថ្មីៗរបស់ក្រសួងពាក់ព័ន្ធនឹងឆ្លុះបញ្ចាំងនៅក្នុងទិន្នន័យថ្មីៗដែលទាក់ទងនឹងសិទ្ធិកុមារ ។ | x | x | |
| | ៣.២.៣- កំណត់សូចនាករ ទម្រង់របាយការណ៍ និងនីតិវិធីក្នុងការរាយការណ៍ជាមួយស្ថាប័នដែលរៀបចំរបាយការណ៍នោះ ។ | ក្រសួងទាំងឡាយនឹងសហការគាំទ្រផ្នែកបច្ចេកទេសដែលចាំបាច់ដើម្បី ដំណើរការប្រព័ន្ធពិនិត្យតាមដាន ។ | x | x | |

| | | | | | |
|---|---|---|---|---|---|
| | ៣.២.៤- កសាងសមត្ថភាពដល់មន្ត្រីសំខាន់ៗក្នុងការប្រមូល នឹងវិភាគទិន្នន័យទាំងផ្នែកគុណភាព និងបរិមាណដើម្បីឱ្យមានជារបាយការណ៍ដែលមានលក្ខណៈសកម្មទុកជាមុន និងប្រកបដោយការពិចារណាល្អិតល្អន់។ | | X | X | |
| | ៣.២.៥- ធ្វើការជាមួយក្រសួងផែនការដើម្បីបញ្ជ្រាបការធ្វើរបាយការណ៍ និងការអនុវត្តស្តីពីសិទ្ធិកុមារចូលទៅក្នុងផែនការជាតិ (ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ) ផែនការតាមវិស័យ និងការធ្វើផែនការថ្នាក់ក្រោមជាតិ។ | | X | X | X |
| | ៣.២.៦- ប្រើប្រាស់ក្រុមការងារ ក.ជ.ក. អនុគណៈកម្មការ និង ក.ជ.ក.ថ្នាក់ខេត្ត ដើម្បីធ្វើ របាយការណ៍អំពីលំហូរទិន្នន័យពីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងធ្វើការកែលម្អទៅតាមការចាំបាច់។ | | X | X | X |

**យុទ្ធសាស្ត្រទី ៤ : ច្បាប់ និងគោលនយោបាយសម្រាប់កុមារ**

**គោលដៅយុទ្ធសាស្ត្រទី ៤ :**

ច្បាប់ និងគោលនយោបាយស្ដីពីការការពារកុមារ នឹងបំពេញតាមតម្រូវការរបស់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ និងតម្រូវការជាអន្តរជាតិផ្សេងទៀត ហើយរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័នមានភារកិច្ចដទៃទៀតនឹងធ្វើសមាហរណកម្មនូវការអនុវត្តនូវកិច្ចការទាំងនេះចូលទៅក្នុងផែនការ និងសកម្មភាពរបស់ខ្លួន ។

| គោលបំណង យុទ្ធសាស្ត្រ | សកម្មភាព | សូចនាករអំពីការបំពេញភារកិច្ច | រយៈពេល | | |
|---|---|---|---|---|---|
| | | | ២០១១ | ២០១២ | ២០១៣ |
| **គោលបំណង ៤.១ :** វិភាគអំពីច្បាប់ និងគោលនយោបាយបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា កំណត់ភាពខ្វះចន្លោះ តស៊ូមតិឱ្យមានការគាំទ្រចំពោះច្បាប់ និងគោលនយោបាយថ្មី ដើម្បីបំពេញឱ្យភាពខ្វះចន្លោះទាំងនេះ និងជួយដល់ការអភិវឌ្ឍនូវភាពខ្វះចន្លោះទាំងនេះ ។ | ៤.១.១- ធ្វើការពិនិត្យឡើងវិញនូវច្បាប់ជាតិ អន្តរជាតិ និងគោលការណ៍ពាក់ព័ន្ធនឹងសិទ្ធិកុមារបច្ចុប្បន្ន ( ឧ.ច្បាប់ពាក់ព័ន្ធនឹងកិច្ចការពារកុមារ ច្បាប់ប្រឆាំងអំពើហិង្សាលើកុមារ ច្បាប់ពាក់ព័ន្ធនឹងកេរមរតក ការបង្កើតតុលាការកុមារ ផែនការសកម្មភាពជាតិសម្រាប់កុមារ ច្បាប់ការងារពាក់ព័ន្ធនឹងកុមារ គោលនយោបាយ និងគោលនយោបាយជាតិតែមួយសម្រាប់កុមារ) ។ | ច្បាប់ និងគោលនយោបាយថ្មីៗ និងផែនការសកម្មភាពជាតិមួយចំនួនត្រូវបានរៀបចំឡើង និងស្ថិតក្នុងដំណើរការនៃការអនុម័ត ។ | x | | |
| | ៤.១.២- ពិនិត្យ នឹងផ្ដល់អនុសាសន៍ជូនរដ្ឋាភិបាលចំពោះច្បាប់ និងកម្មវិធីសកម្មភាពជាតិនានា ដូចដែលកំណត់ខាងលើ ។ | មានការប្រជុំមួយចំនួនជាមួយមន្ត្រីរដ្ឋាភិបាល ។ | x | x | x |
| | ៤.១.៣- ធ្វើសេចក្ដីព្រាងច្បាប់ និងគោលនយោបាយស្ដីពី | តំណាងកុមារមួយចំនួន និង ជនពិការជនជាតិ | x | x | x |

| | | | | | |
|---|---|---|---|---|---|
| | សិទ្ធិកុមារ និងផែនការសកម្មភាពជាតិ ឧ.ផែនការសកម្មភាពជាតិសម្រាប់កុមារ ច្បាប់ពាក់ព័ន្ធនឹងកេរមរតក ការបង្កើតតុលាការអនីតិជន គោលនយោបាយជាតិស្តីពីកុមារ ។ | ភាគតិច និងតុល្យភាពនៃសមភាពយេនឌ័រមាននៅក្នុងការរៀបចំច្បាប់ និងគោលនយោបាយថ្មីៗ ។ | | | |
| | ៤.១.៤- ធ្វើការពិគ្រោះយោបល់ដើម្បីធានាថា ច្បាប់ និងគោលនយោបាយទាំងឡាយមានបញ្ចូលពាក់ព័ន្ធនឹងយេនឌ័រ ពិការភាព និងជាតិពន្ធុ ។ | | x | x | x |
| | ៤.១.៥- ធ្វើការប្រឹក្សាយោបល់ជាលក្ខណៈប្រព័ន្ធជាមួយកុមារ និងអង្គការមិនមែនរដ្ឋាភិបាលស្តីពីច្បាប់ និងគោលនយោបាយថ្មីៗ និងផែនការសកម្មភាពនានា ។ | | x | x | x |
| **គោលបំណង ៤.២ :** ធានាថាច្បាប់ និងគោលនយោបាយថ្មីៗត្រូវបានធ្វើសមាហរណកម្មចូលទៅក្នុងផែនការតាមវិស័យរបស់រាជរដ្ឋាភិបាល និងផែនការរបស់អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងកម្មវិធីលើកកម្ពស់ការយល់ដឹងនៅ | ៤.២.១- រៀបចំបង្កើតគោលការណ៍ណែនាំសម្រាប់ការបញ្ជ្រាបច្បាប់ថ្មីៗ និងផែនការសកម្មភាពជាតិ និងគោលនយោបាយសំដៅចំពោះមន្ត្រីអនុវត្ត ។ | ក្រសួងរបស់រាជរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ខេត្តមួយចំនួន អង្គការមិនមែនរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍមានការយល់ដឹងអំពីច្បាប់ គោលនយោបាយ និងផែនការសកម្មភាពជាតិនានា ។ | x | x | |
| | ៤.២.២- ធ្វើការបណ្តុះបណ្តាលគ្រូបង្គោលស្តីពីច្បាប់ពាក់ព័ន្ធនឹងសិទ្ធិកុមារ ផែនការសកម្មភាពជាតិ និងការអនុវត្តគោល | ឧបករណ៍ថ្មីៗត្រូវបានអភិវឌ្ឍដើម្បីវាស់ស្ទង់ការអនុវត្តច្បាប់ ផែនការសកម្មភាពជាតិ និង | x | x | x |

| | | | | | |
|---|---|---|---|---|---|
| គ្រប់លំដាប់ថ្នាក់ទាំងអស់ ។ | នយោបាយនៅថ្នាក់ដែលពាក់ព័ន្ធ ឧ.មន្ត្រីរាជរដ្ឋាភិបាល កុមារ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍនានា ។ | គោលនយោបាយជាតិទាំងឡាយ ។ | | | |
| | ៤.២.៣- ធ្វើសមាហរណកម្មច្បាប់ថ្មីៗ ផែនការសកម្មភាពជាតិ និងគោលនយោបាយទាំងឡាយចូលទៅក្នុងប្រព័ន្ធផ្សព្វផ្សាយនិងយុទ្ធនាការលើកកម្ពស់ការយល់ដឹង ។ | | x | x | x |
| | ៤.២.៤- បង្កើតឧបករណ៍សម្រាប់វិភាគ វាយតម្លៃឱ្យដល់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍទាំងឡាយ ដើម្បីឱ្យពួកគេប្រាកដថា ពួកគេបានអនុវត្តទៅតាមច្បាប់ ផែនការសកម្មភាពជាតិ និងគោលនយោបាយថ្មីៗ ។ | | x | x | x |

~~~~~~~~~~~~~~~
~~~~~~~~~~~~~~~